រឿង

# មានទឹកឃើញ

# លោកពុកម្នាក់នោះអត់?

ប៊ូ វាសនា

ជូនចំពោះ

------------------------------------

ហត្ថលេខាអ្នកកាន់សៀវភៅ

------------------------------------

# អារម្ភកថា

*«មានទឹកឃើញលោកពុកម្នាក់នោះអត់?»* ដែលលោកអ្នកកំពុងតែកាន់នៅនឹងដៃរបស់លោកអ្នកនេះ គឺជាស្នាដៃតាក់តែងនិពន្ធសាច់រឿងខ្លីទី២របស់ខ្ញុំបាទដែលបានតាក់តែងនិពន្ធ រិះរកគំនិតសាច់រឿងមកចងក្រងជាសាច់រឿងខ្លីមួយនេះ។ ស្នាដៃនិពន្ធសាច់រឿងខ្លីមួយនេះគឺតាក់តែងឡើងអោយខេមរជនដែលជាយុវជនទាំងអស់អានក្នុងគោលបំណងអោយយុវជនគ្រប់រូបយល់ពីទឹកចិត្តដ៏ធំធេងដែលពុំអាចកាត់ថ្លៃបាន និងយល់នូវទំហំនៃសេចក្ដីស្រលាញ់ ការលះបង់របស់អ្នកមានគុណ។ បន្ទាប់ពីខ្ញុំបាទបានទទួលនូវជ័យលាភីលេខ២ ក្នុងការប្រលងប្រកួតប្រជែងវណ្ណកម្មកម្រិតយុវជនរបស់សាលាអន្តរជាតិ ខេន រីដ (Kent Ridge International School) នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ មក ខ្ញុំបាទបានទទួលនូវបទពិសោធន៍ជាច្រើនក្នុងការសិក្សាស្រាវជ្រាវបន្ថែមក្នុងការតាក់តែងនិពន្ធ

ស្គាល់នូវសមត្ថភាពពិតរបស់ខ្លួន ទទួលបានការយល់ដឹងបន្ថែមក្នុងការរិះរកគំនិតសាច់រឿង មកសរសេរតាក់តែងជាសាច់រឿងខ្នាតខ្លីដំបូងបង្អស់ និង ស្គាល់ពីភាពលំបាកក្នុងការតាក់តែងនិពន្ធជាសាច់រឿង។ ស្នាដៃនិពន្ធសាច់រឿងខ្នាតខ្លីដែលខ្ញុំបាទបានតាក់តែងនិពន្ធដំបូងបង្អស់នោះមានចំណងជើងថា **«គុកឥតជញ្ជាំង»** ដែលនៅក្នុងសាច់រឿងគុកឥតជញ្ជាំងនេះដែរគឺសរសេរអំពីជីវិតរបស់តួអង្គឯកក្មេងស្រីឈ្មោះ **សុរិយា** ដែលនាងបានជួបប្រទះក៏ដូចជាឆ្លងកាត់សម័យរបបកម្ពុជាប្រជាធិបតេយ្យ (សម័យ ប៉ុល ពត) ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ ស្នាដៃនិពន្ធសាច់រឿងខ្នាតខ្លីទី២រឿង **«មាននឹកឃើញលោកពុកម្នាក់នោះអត់?»** នឹងនាំអ្នកអានទាំងអស់ទៅជួបទិដ្ឋភាពខ្សែជីវិតរបស់បុរសពោះម៉ាយម្នាក់ដែលគាត់ចិញ្ចឹមកូនប្រុសពីរនាក់ថា តើសកម្មភាពដំណើររឿង ឬ ខ្សែជីវិតរបស់បុរសពោះម៉ាយ និងកូនប្រុសពីរនាក់ទៀតទៅជាបែបណាទៅ? រីឯតម្លៃអប់រំនៃសាច់រឿងនឹងប្រាប់អ្នកអានទាំងអស់នៅចុងទំព័រនៃសាច់រឿងខ្នាតខ្លីមួយនេះ។

ដូចនេះ ក្នុងនាមខ្ញុំបាទជាអ្នកតាក់តែងនិពន្ធសាច់រឿងខ្លាតខ្វីមួយនេះត្រៀមរួចជាស្រេចក្នុងការស្វាគមន៍ទទួលនូវមតិ និង ការវាយតម្លៃរបស់លោកអ្នក។

សូមអរគុណ៕

ភ្នំពេញ, ថ្ងៃ អង្គារ ទី០១ ខែ មិថុនា ឆ្នាំ ២០២១

អ្នកតាក់តែងនិពន្ធសាច់រឿងខ្លាតខ្វី

**ប៊ូ វាសនា**

(អតីតបេក្ខជនម្ចាស់ជ័យលាភីលេខ ២ ក្នុងការប្រលងប្រកួតប្រជែងវណ្ណកម្មកម្រិតយុវជនឆ្នាំ ២០១៩ និងបច្ចុប្បន្នជានិស្សិតឆ្នាំទី១ ផ្នែក អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមសម្តែងនូវថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូ ដែលជាលោកឪពុកអ្នក ម្តាយទីពីរ ដែលពួកគាត់បានផ្តល់នូវចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅ។ ទន្ទឹមនឹងនោះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់រៀមច្បង លោកគ្រូអ្នកគ្រូ ឪពុកអ្នកម្តាយ មិត្តភក្តិទាំងអស់ម្តងទៀត ដែលពួកគាត់តែងតែលើកទឹកចិត្តខ្ញុំអោយមានភាពក្លាហានបន្ថែមទៀត។ ជាពិសេសអ្នកមានគុណទាំងពីរដែលលោកបានចិញ្ចឹមបីបាច់ថែរក្សាបណ្តុះបណ្តាល មេរៀនជីវិត គុណរបស់លោកពុំអាចកាត់ថ្លៃបាននោះទេ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ ពួកគាត់ថែមទាំង ជម្រុញខ្ញុំអោយចូលរួកម្មវិធីប្រលងប្រកួតប្រជែងវណ្ណកម្មកម្រិតយុវជនឆ្នាំ ២០១៩ របស់សាលាអន្តរជាតិ ខេន រីជ (Kent Ridge International School)។

ពុំដូច្នោះនោះទេខ្ញុំបាទនឹងគ្មានកម្លាំងចិត្ត និង សមត្ថភាព ក្នុងការចូលប្រលងប្រកួតប្រជែងនោះទេគឺមកពីការ ជម្រុញលើកទឹកចិត្ត និង បណ្តុះភាពក្លាហានខ្លួនឯង។ សូមអរគុណសម្រាប់ការចែករំលែក ចំណេះដឹង គំនិតល្អៗ ក៏ដូចជាបទពិសោធន៍ ដែលធ្វើឱ្យ ស្នាដៃនិពន្ធសាច់រឿង ខ្នាតខ្លីមួយនេះសម្រេចបានជោគជ័យជាស្ថាពរ។

រាជធានីភ្នំពេញ, ថ្ងៃ អង្គារ ទី០១ ខែ មិថុនា ឆ្នាំ ២០២១

អ្នកតាក់តែងនិពន្ធសាច់រឿងខ្នាតខ្លី

**ប៊ូ វាសនា**

# ផ្តើមសេចក្តី

# នៃសាច់រឿង

ព្រះអាទិត្យចាប់ផ្ដើមរះពីទិសខាងកើតបន្តិចម្ដងៗ បានបញ្ចេញនូវរស្មីបំភ្លឺខេត្តត្បូងឃ្មុំគួបផ្សំជាមួយខ្យល់ត្រជាក់នារដូវធ្លាក់ខ្យល់ ។ អាកាសធាតុដ៏ត្រជាក់ខ្យល់ក៏កំពុងបក់ផាយផាត់មកប៉ះអ្នកភូមិដែលកំពុងតែធ្វើដំណើរនៅក្នុងភូមិ។ សម្លេងមាន់រងាវបន្លឺឡើងអោយលឺដល់អ្នកភូមិ ឬ គ្រួសារនីមួយៗងើបពីដំណេក រៀបចំពូកគ្រែ រៀបចំទៅងូតទឹក ទៅរកដុំឈើ ធ្យូង អូស ដែកកេះ ដើម្បីបង្កាត់ភ្លើងដើម្បីដាំទឹក ដាំបាយ ធ្វើម្ហូបអោយសមាជិកគ្រួសារនីមួយៗ នាំគ្នាប្រញាប់មកស្រស់ស្រូបអាហារពេលព្រឹកទៅធ្វើការ និង កូនៗទៅសាលារៀនរៀងៗខ្លួន។ ទន្ទឹមនឹងនោះ មានផ្ទះតូចល្មមមួយនៅក្នុងភូមិ ហាក់បីដូចជា ផ្ទះតូចល្មមមួយនោះមានមនុស្សរស់នៅបែបជាលក្ខណៈគ្រួសារតូចមួយ នោះគឺជាគ្រួសាររបស់ពូលាភ។

# ទិដ្ឋភាពគ្រួសារ

# របស់ពូលាក

ពូលាភ ជាពោះម៉ាយម្នាក់ដែលមានកូនប្រុសពីរនាក់ រស់នៅជាមួយ។ តាំងពីប្រពន្ធរបស់ពូលាភបាន លាចាក លោកដោយសារជំងឺប្រចាំកាយ បាត់ទៅនៅក្នុងខ្លួន ពូលាភមានតែផ្ទះតូចល្មមមួយ ទ្រព្យសម្បត្តិខ្លះៗ ដែល អាចនឹងល្មមចិញ្ចឹមកូនប្រុសពីរនាក់របស់គាត់រស់។ រីឯ ជីវភាពរបស់ក្រុមគ្រួសាររបស់គាត់វិញ គឺស្ថានភាពរបស់ ក្រុមគ្រួសារពូលាភមិនជាក្រប៉ុន្មាននោះទេ ពីព្រោះ ពូលាភ គាត់សព្វថ្ងៃធ្វើការជាកម្មករសំណង់វេនថ្ងៃ ទាល់តែថ្ងៃលិច ទើបគាត់ត្រលប់មកពីធ្វើការវិញ។ ទីកន្លែងធ្វើការរបស់ គាត់គឺនៅមិនជិតពីផ្ទះ របស់គាត់នោះទេ ពីផ្ទះរបស់គាត់ ទៅ ទីកន្លែងធ្វើការសំណង់មានចម្ងាយ១០គីឡូម៉ែត្រ។ ថ្វីត្បិតតែពូលាភបានបាត់បង់ប្រពន្ធជាទីស្រលាញ់របស់ គាត់ក៏ពិតមែន តែគាត់នៅតែតស៊ូព្យាយាម ពុះពារ នូវរាល់ឧបសគ្គ ដែលគាត់នឹងជួបប្រទះតទៅថ្ងៃមុខ។ មិនត្រឹមតែប៉ុណ្ណោះ គាត់នៅតែមានកម្លាំងធ្វើការដើម្បីកូន ប្រុសពីរនាក់របស់គាត់។ គាត់ជាមនុស្សព្យាយាម មិនដែល រអ៊ូ ត្អូញត្អែរ ចំពោះការងារ ឬ ភារកិច្ចរបស់គាត់នោះឡើយ

ពោល គឺ គាត់នៅតែដើរតួបន្តជាលោកពុកដ៏ល្អ ចំពោះមុខកូនប្រុសពីរនាក់របស់គាត់។ អ្វីដែលជាកាតព្វកិច្ចរបស់គាត់ក្នុងនាមជាលោកពុកផង កម្មករសំណង់ផង គប្បីទទួលខុសត្រូវនៅក្នុងសង្គមគ្រួសារ ដើម្បីជីវិត និង ជីវភាព។ ទាន់គាត់នៅមានកម្លាំង គាត់ត្រូវបំពេញតួនាទីរបស់គាត់។ ប្រជាជននៅក្នុងភូមិនោះកាលដែលឃើញនូវរាល់សកម្មភាព ក៏ដូចជាទង្វើរបស់គាត់ ក៏កើតសេចក្តីស្រលាញ់រាប់អាន ចេះចែករំលែកគ្នាទៅវិញទៅមកផ្តល់ភាពកក់ក្តៅពីគ្នាទៅគ្នា ជួយពេលគាត់មានភាពលំបាក រួបរួមសាមគ្គីគ្នាថែមទៀតផង។ ប្រសិនបើនិយាយពីការប្រកបមុខរបររបស់ពូលាភវិញ ទោះបីជាគេអោយគាត់ធ្វើការជាកម្មករសំណង់ដូចជា លើកបាវដីខ្សាច់ បញ្ជូនដុំឥដ្ឋ រៀបដុំឥដ្ឋ លាបថ្នាំពណ៌នៅតាមជញ្ជាំងផ្ទះក៏ដោយ ក៏ពូលាភហ៊ានទទួល និងប្រឈមទៅនឹងការងារបែបហ្នឹងដែរ ក៏ប៉ុន្តែការងាររបស់ពូលាភជាប្រភេទការងារប្រើប្រាស់កម្លាំងកាយ ទាមទារកម្លាំងពេញលេញ រាងកាយស្វាហាប់មាំមួន សុខភាពល្អ

ជាពិសេសគឺការលាបថ្នាំពណ៌នៅតាមជញ្ជាំងផ្ទះជាដើមគឺ ថា បើអ្នកដែលមានប្រតិកម្មទៅនឹងពពួកថ្នាំដែលត្រូវបាន គេប្រើប្រាស់ដើម្បីលាបនៅតាមជញ្ជាំងផ្ទះឬមានសុខភាព មិនសូវល្អនោះទេ បើមានការធ្វេសប្រហែសនោះ សារធាតុ ថ្នាំលាបជញ្ជាំងនោះ ក្លិនរបស់វាចូលទៅក្នុងសួតដែលអាច នឹងបណ្តាលអោយខូចសរីរាង្គខាងក្នុង វងការខូចខាត នូវ ប្រព័ន្ធដំណកដង្ហើមរបស់មនុស្សថែមទៀតផង។ វាអាចជា ហានិភ័យមួយសម្រាប់អ្នកដែលជាកម្មករសំណង់ (លាបថ្នាំនៅតាមជញ្ជាំងផ្ទះ)។ ប៉ុន្តែចំពោះពូលាភ គឺគាត់ គ្មានជម្រើសនោះទេប្រសិនបើគាត់មិនប្រកបការងារជា កម្មករសំណង់នោះទេគឺគាត់ប្រាកដជាគ្មានការងារធ្វើតទៅ ទៀតនោះទេ។ មិនត្រឹមតែប៉ុណ្ណោះនោះទេគាត់នឹងគ្មាន ប្រាក់កម្រៃ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ នោះឡើយពោលគឺ គ្មានប្រាក់កម្រៃសន្សំទុកអោយកូនប្រុសរបស់គាត់ទាំងពីរ នាក់ទុកអោយចាយវាយ ទិញសម្ភាររៀនសូត្ររបស់របរ ប្រើប្រាស់គ្មានលុយក្នុងការទិញម្ហូបអាហារដើម្បីបំពេញ តម្រូវការនៃការស្រេកឃ្លាននៃក្រពះ

សម្លៀកបំពាក់ ដើម្បីបំពេញតម្រូវការរបស់គាត់និងកូនប្រុសរបស់គាត់ពីរនាក់ផងដែរ។ ដោយសារតែ ពូលាភជាពោះម៉ាយផង ចិញ្ចឹមកូនប្រុសរបស់គាត់ទៀត គាត់មិនអស់សង្ឃឹមនោះឡើយ គាត់នៅតែខំប្រឹងពុះពារជរាបណាគាត់នៅមានកម្លាំង មានដង្ហើម គឺគាត់នៅតែបន្តបំពេញកាតព្វកិច្ច ជាលោកពុកដ៏ល្អ អោយកូនប្រុសរបស់គាត់រៀនចប់ចុងចប់ដើមរហូតអោយកូនប្រុសគាត់មានការងារល្អៗធ្វើ ចង់អោយកូនៗរបស់គាត់មានមុខមាត់ មានកេរ្តិ៍ឈ្មោះផ្តល់កិត្តិយសអោយលោកពុក លោកពុកមិនចង់បានអ្វីច្រើននោះទេ គឺចង់អោយកូនៗរបស់ខ្លួនរស់នៅប្រកបដោយសេចក្តីសុខដុមរមនា សុភមង្គលនៅថ្ងៃមុខនិង ការតបស្នងអ្នកមានគុណ។ លោកពុកសុខចិត្តទទួលបន្ទុកធ្ងន់ លោកពុកគ្រាន់តែចង់ឃើញកូនៗមានសេចក្តីសុខ ស្នាមញញឹម រៀនពូកែ គេកោតសរសើរ។

# កូនប្រុសពីរនាក់

# របស់ពូលាភ

កូនប្រុសពីរនាក់របស់ពូលាភមានឈ្មោះ កូនប្រុសទី១ ឈ្មោះ ពន្លឺ ដែលត្រូវជាកូនបងនៅក្នុងគ្រួសារ។ រីឯកូនប្រុសទី២ ឈ្មោះ ពន្លក ដែលត្រូវជាកូនប្អូននៅក្នុងគ្រួសារតូចមួយនេះ។ កូនប្រុសបងឈ្មោះ ពន្លឺ បានរៀនចប់កម្រិតវិទ្យាល័យ (ថ្នាក់ទី១២ ឬ ថ្នាក់ប្រលងមធ្យមសិក្សាទុតិយភូមិ ) ព្រមទាំងទទួលបាននូវ លទ្ធផលនិទ្ទេសល្អបង្គួរទៀតផង។ បច្ចុប្បន្នគេមានអាយុ ២០ឆ្នាំ ហើយតែគេពុំទាន់រកសាកលវិទ្យាល័យណាមួយដើម្បីរៀនបន្តនោះឡើយ ពីព្រោះគេចង់មកជួយសម្រួលបន្ទុករបស់លោកពុករបស់គាត់ដោយគាត់ឃើញភាពទុក្ខលំបាករបស់លោកពុករបស់ខ្លួន ដូច្នេះ គាត់ក៏យកពេលទៅជួយសម្រួលបន្ទុករបស់លោកពុករបស់គាត់ដែលជាពូលាភ កុំអោយគិតថាអត់បានធ្វើអ្វីទាល់តែសោះ។ មូលហេតុមួយទៀត ដែលគាត់ពុំទាន់មានគម្រោងទៅរៀនតនៅសាកលវិទ្យាល័យ ព្រោះគាត់ចង់ធ្វើការសម្រាកខួរក្បាលពីការរៀនសូត្រអោយបានមួយរយៈសិន បែរមកជួយកិច្ចការនៅផ្ទះវិញសិនដូចជា មើលថែទាំផ្ទះសម្បែង មើលវាលស្រែគោក្របី ស្រែចម្ការ

កសិដ្ឋាន មាន់ ទា ជ្រូក ព្រាប រៀបចំទុកដាក់ទ្រព្យសម្បត្តិ មើលខុសត្រូវជុំវិញផ្ទះ ជាដើម។ រីឯ កូនប្រុសពៅ ពន្លក ឯណោះវិញ គាត់មានអាយុ ១៧ឆ្នាំ ហើយគាត់បច្ចុប្បន្នជាសិស្សថ្នាក់ទី១១ នៅឯវិទ្យាល័យមួយក្នុងភូមិ។ ថ្វីត្បិតតែកូនប្រុសទាំងពីរនោះជា បងប្អូនបង្កើតក៏ពិតមែន ក៏ប៉ុន្តែបើនិយាយពីឥរិយាបទ ចរិតមាយាទ អាកប្បកិរិយា សុជីវធម៌ និង សីលធម៌ រវាងកូនប្រុសពីរនាក់នេះវិញ មានភាពខុសពីគ្នាដាច់ណាស់។ ពន្លឺដែលជាកូនប្រុសបងក្នុងគ្រួសារ ជាមនុស្ស ប្រកបដោយភាពថ្លៃថ្នូរដឹងខុសត្រូវសុភាពស្គាល់ចាស់ស្គាល់ទុំ មិនចេះមាត់ច្រើនពេកនោះទេ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ ពន្លឺជាមនុស្សប្រកបដោយចំណេះដឹង ចំណេះធ្វើជំនាញដែលពូលាកបានបង្រៀន។ មួយវិញទៀត ពន្លឺជាមនុស្សចូលចិត្តលើកទឹកចិត្តមនុស្ស ផ្តល់ភាពកក់ក្តៅសេចក្តីស្រលាញ់ទៅមនុស្សជុំវិញខ្លួន។

មិនថាអ្នកនៅក្នុងភូមិ កាលគាត់ជាសិស្សវិទ្យាល័យក៏ដោយ សូម្បីតែគ្រូនៅទីចាត់ការមិនថា គ្រូនាយក មិត្តភក្តិ ពួកគាត់ កើតសេចក្តីកោតសរសើរស្រលាញ់ រាប់អាន ចំពោះពន្លឺ ណាស់ដោយអ្នកភូមិ គ្រូបង្រៀន គ្រូនាយក នឹង មនុស្សជុំវិញខ្លួនវា មនុស្សដូចជា ពន្លឺនេះសាកសមជាបុគ្គលល្អមួយរូប ជាធនធានមនុស្សនៅក្នុងសង្គមដ៏ល្អប្រពៃនៅថ្ងៃមុខ មិនត្រឹមតែល្អប្រពៃនៅក្នុងសង្គមនោះទេ សង្គមគ្រួសារផងដែរ ព្រោះតែជាមនុស្សមានសីលធម៌ មានទំនុកចិត្ត ដែលអាចពឹងពាក់បាន។ ពន្លឺមិនត្រឹមតែជាបុគ្គលបែបនោះប៉ុណ្ណោះទេ ថែមទាំងជាមនុស្សប្រកបដោយឆន្ទៈក្តាប់គោលបំណងរបស់ខ្លួនយ៉ាងមុតមាំ ធ្វើអ្វីប្រកបដោយប្រុងប្រយ័ត្ន ពេលនរណាម្នាក់ ឬ ក៏មានមនុស្សសុំជំនួយពីគាត់ ពន្លឺពុំជំទាស់នោះឡើយ អ្វីដែលគាត់មាន គាត់ចេះ គឺគាត់ចែករំលែកជូនដោយចេញពីចិត្ត តែចំណុចមួយរបស់គាត់នោះគឺ ពន្លឺមិនចូលចិត្តមនុស្សរឹងរូស មិនស្តាប់បង្គាប់ដំបូន្មាននោះទេ។ គាត់នឹងប្រើប្រាស់ពាក្យសម្តីមិនសមរម្យ មិនពិរោះបន្តិចបន្តួច តែក្នុងន័យអប់រំចង់អោយមនុស្សមាន

ការកែប្រែកំហុសដឹងកំហុសដែលមនុស្សប្រព្រឹត្តកែប្រែកំហុសទាន់មានឱកាស ផ្លាស់ប្តូរផ្នត់គំនិត និង ទម្លាប់ដែលមិនល្អ អ្វីដែលគួរធ្វើឬមិនគួរធ្វើ។ ពន្លឺក៏តែងតែប្រាប់និងបង្រៀនមនុស្សជុំវិញខ្លួនថា៖ « ជាទូទៅមនុស្សយើងគ្រប់ស្រទាប់វណ្ណៈ មិនមែនធ្វើអ្វីត្រូវល្អឥតខ្ចោះឡើយពោលគឺពួកគាត់តែងតែជួបនូវកំហុសខុសឆ្គងហើយរាល់កំហុសទាំងនោះជួនកាលវាអាចជាកំហុស ច្ចេតនា ឬ អច្ចេតនា ធំ ឬ តូច។ មនុស្សយើងកើតមកមានសិទ្ធិក្នុងការរៀបចំជីវិតរបស់ខ្លួន អោយមានតម្លៃល្អប្រពៃព្រមទាំងអោយវៀរចាកនូវអ្វីដែលខុសមិនគប្បីហើយនោះទើបការរស់នៅប្រកបដោយភាពថ្លៃថ្នូរមានន័យនិងមានប្រយោជន៍ចំពោះគ្រួសារនិងសង្គម។ បើយើងគិតអោយជ្រៅទៅកំហុសដ៏តូចមួយប្រៀបបានទៅនឹងស្នាមប្រឡាក់ ឬ ស្នាមប្រេះនៃរបស់អ្វីមួយដែលទុកយូរទៅមិនអាចនឹងលាងជម្រះបាន ហើយស្នាមប្រេះ នោះ នឹងរីករាលដាលធំទៅៗ រហូតធ្វើអោយរបស់មួយនោះ ខ្ទេចខ្ទាំ ឬ ទៅជា បំណែកតូចៗ។

យ៉ាងណាមិញកំហុសតូចទេតែបើយើងចេះតែទុកបណ្តោយអោយវាដុះរីករាលដាលកាន់តែធំឡើងនោះនឹងអោយបង្កភាពមហន្តរាយដល់ខ្លួនឯងនិងសង្គមជាតិទៀតផង។ ទន្ទឹមនឹងនេះ ការចេះស្គាល់កំហុសនិងការកែប្រែកំហុសរបស់ខ្លួនដែលខ្លួនប្រព្រឹត្ត គឺជាវិធីដ៏ល្អមួយដែលឆ្លុះបញ្ចាំងពីការដឹងខុស ការដែលចេះទទួលខុសត្រូវភាពសច្ចៈយុត្តិធម៌ នឹងបន្តខ្លួនអោយក្លាយទៅជាមនុស្សមានតម្លៃក្នុងសង្គមជាតិ ព្រមទាំងគ្រួសារជាដើម។ ដូច្នេះពន្លឺមានន័យថាមិនថាកំហុសដែលយើងប្រព្រឹត្តនោះតូចក្តី ឬ ធំក្តីបើយើងដឹងខុសដឹងខ្លួនថាបានប្រព្រឹត្ត ចូរអ្នកគប្បីចេះកែប្រែកំហុសទាន់មានឱកាស កុំឲ្យវាហួសពេល និង កុំបណ្តោយអោយវាបង្ករឿងធំ អោយបង្កមានភាពវិប្បដិសារី និង មហន្តរាយដល់ខ្លួន និង អ្នកដទៃទៀត។ វត្ថុបំណងរបស់មនុស្សគ្រប់រូប គ្មានអ្វីក្រៅពីចង់អោយខ្លួន ក្លាយជាធនធានមនុស្សក៏ល្អនៅថ្ងៃមុខនោះទេ អាចនិយាយបានថា ជាបុគ្គលគំរូក្នុងសង្គមជាតិនិង មនុស្សជុំវិញខ្លួនដូចបានគេលើកឡើងថា

" **យុវជនជាសសរទ្រូងរបស់ជាតិ** " និងមួយទៀត " **យុវជនជាទំពាំងស្នងឬស្សី** "»។ រាល់នូវពាក្យសម្តី ការបកស្រាយបង្រៀន បណ្តុះបណ្តាលរបស់ពន្លឺបានធ្វើឲ្យមនុស្សជុំវិញខ្លួនមានការដឹងខ្លួននិងរៀនពីពន្លឺអោយបានច្រើននិងយកគំរូពីពន្លឺ។ បើក្រឡេកទៅមើលកូនប្អូនរបស់ពូលាភវិញដែលមានឈ្មោះថា ពន្លកនោះ ចំនុចដែលពន្លកខុសដាច់ពីពន្លឺនិងពូលាភដែលជាលោកពុកនោះគឺ កូនប្អូនលេងសើចច្រើន ប្រហើនជាមួយបងប្រុសនិងលោកពុក មិនយកចិត្តទុកដាក់។ បន្ថែមលើនេះទៅទៀតបើនិយាយពីសំដីសំដៅវិញគឺថា ដូចលាមក មិនពិរោះភាសា។ ការប្រើប្រាស់ពាក្យសម្តី មិនល្អប្រពៃ ឈ្លើយ មិនស្គាល់ខុសស្គាល់ត្រូវហើយថែមទាំងដើរជាមួយក្រុមសិស្សមិនល្អទៀតផង។ ទោះបីជា គ្រូបាអាចារ្យ ព្រះឥន្ទ្រណាមកប្រដៅក៏មិនទៅមុខដែរ មនុស្សប្រភេទដូចជា ពន្លកហ្នឹង ប្រដៅមិនកើតដូចជាមិនចេះស្តាប់គ្នាសោះសូម្បីបងរបស់ខ្លួន លោកពុករបស់ខ្លួន។

មនុស្សដូចជាពន្លកពិបាកទទួលយកខ្ចិលប្រអូស ក៏ប៉ុន្តែចំពោះលោកពុក និង ពន្លឺដែលជាបងប្រុសនោះ ទោះបីជាកូនប្អូន ឬ ប្អូនប្រុសរបស់ខ្លួនទៅជាយ៉ាងណាក៏ដោយទាន់លោកពុកម្នាក់នេះនៅមានកម្លាំងគាត់នៅតែប្រៀនប្រដៅទូន្មាន ទោះបីជាគាត់ប្រើប្រាស់ពាក្យមិនសមរម្យ សម្ដីជ្រុលចំពោះកូនប្អូនក៏ដោយ ក៏ព្រោះលោកពុកស្រលាញ់ពន្លកចង់ឃើញកូនកែប្រែទម្លាប់អាក្រក់ចោល កែប្រែកំហុស ទង្វើ ឬ សកម្មភាពមិនគប្បី អ្វីដែរគួរធ្វើ ឬ មិនគួរធ្វើទាន់មានឱកាស។ ពូលាភអោយតែពេលឃើញនូវរាល់សកម្មភាពរបស់ពន្លកដូច្នោះ ពន្លកជាមនុស្សបែបហ្នឹង ទោះបីជាកូនទៅជាយ៉ាងណាក៏ដោយក៏កូននៅតែជាកូនប្រុសរបស់ពុក។ ពូលាភកើតក្ដីបារម្ភចំពោះពន្លកជាខ្លាំងដែលកូនរបស់ខ្លួនធ្វើអ្វីតាមទំនើងចិត្តមិនចេះស្ដាប់គ្នា សំខាន់នៅវ័យកំពុងតែលូតលាស់វ័យសិក្សាទៀតខ្លាចកូនរបស់ខ្លួនដើរផ្លូវខុស។ ប៉ុន្តែពូលាភក៏ធូរស្រាលចិត្តពាក់កណ្ដាលដែលមានកូនពន្លឺនៅជិតជាមនុស្សល្អ។

តាមពិតទៅក្នុងនាមជាមាតាបិតាគ្រប់រូប មិនដែលមានចិត្ត ស្អប់កូនៗរបស់ខ្លួននោះទេ គ្រាន់តែពួកគាត់បារម្ភ ភ័យខ្លាច ថាកូនដើរសេពគប់មនុស្សមិនល្អ ពីព្រោះក្នុងសង្គមនីមួយៗ ក្រុមមនុស្សក្នុងសង្គមសឹងតែមានគ្រប់ប្រភេទ ខ្លាចកូនៗ របស់ខ្លួនដើរលើ វិថីខុស និង គ្រាន់តែមិនចូលចិត្តទង្វើ សកម្មភាព របស់កូនៗដែលប្រព្រឹត្តទៅមិនល្អហើយមានតែ ជួយតម្រង់ទិសកូន អោយដើរផ្លូវល្អ ផ្លាស់ប្តូរផ្នត់គំនិតកូនៗ ហើយអ្វីដែលពួកគាត់ចង់បានគឺ ចង់ឃើញកូនៗ ទៅថ្ងៃមុខ មានភាពរុងរឿង មានការអភិវឌ្ឍន៍ រស់នៅប្រកបដោយ សេចក្តីសុខសប្បាយ សុខដុមរមនា មិនចង់ឃើញផ្នែក អវិជ្ជមានរបស់កូនឡើយ។ ចង់ឃើញកូនមានកិត្តិយសមាន មុខមានមាត់។

# ព្រឹកព្រលឹមស្រាងៗ

# ក្រោមដំបូលផ្ទះ

# ពូលាក

នាពេលព្រឹកព្រលឹមស្រាងៗដ៏គួរអោយស្រស់ស្រាយមួយ អមដោយបរិយាកាសត្រជាក់ និង ខ្យល់ចេញចូលក្នុងរដូវធ្លាក់ខ្យល់ ។ សម្លេងមាន់រងាវក៏បន្លឺឡើងដាស់អ្នកភូមិអោយងើបពីដំណេក អោយមានចលនាធ្វើ ពលកម្មទាំងព្រឹក។ ព្រះសុរិយាក៏បានបញ្ចេញពន្លឺព្រះអាទិត្យទាំងចាំងចូលតាមបង្អួចនៃផ្ទះពូលាភ ធ្វើអោយពូលាភភ្ញាក់ពីដំណេកស្របពេលដែលពន្លឺភ្ញាក់ពីដំណេកផងក៏នាំគ្នាងើបស្ទុះស្ទារៀបចំគ្រែ ពូក ខ្នើយ ភួយ បន្ទប់គេងអោយបានស្អាតបាត។ លើកលែងតែពន្លកទេ ដែលមិនទាន់ងើបនោះ។ ដោយឃើញ ទិដ្ឋភាពនោះ ភ្លាមៗនោះ ពន្លឺក៏ដាស់ពន្លកថា៖

**ពន្លឺ ៖** ពន្លក ? ពន្លក ? ពន្លក ? នែ ពន្លក!!

**ពន្លក ៖** ហើយ! អីទៀតហើយ

**ពន្លឺ ៖** ងើបឡើងមើល ព្រះអាទិត្យរះហើយណា ! ចាំអង្គាល់ទៀតអោយវារស់រវើកស្ទុះស្ទា បន្តិចទៅមើល ដូចពិបាកម៉េស លោកប្អូន អើយលោកប្អូន !

ពេលនោះពន្លកក៏ឆ្លើយតបទៅនឹងបងប្រុសខ្លួនឯង ហាក់បីដូចជាពុំទាន់អស់ងងុយគេងថា៖

**ពន្លក ៖** ហើយ!!! ធុញហាស ! (រអ៊ូក្នុងចិត្ត) ដឹងហើយបងអោយបន្តិចទៀតមើល អាត្មាមិនទាន់ដេកឆ្អែតផង។

**ពន្លឺ ៖** ពិនិត្យពាក្យសម្តី ពន្លកឯងនិយាយម្តងម្តងទៀតមើលជាមួយបងសុទ្ធតែប្រើប្រាស់ពាក្យ " ដេក "។

**ពន្លក ៖** កុំនិយាយច្រើនពេកមើល ទ្រឹស្តីទាំងព្រឹក។

(ពន្លកយកខ្នើយខ្ទប់មុខ)

ពន្លឺដកដង្ហើមធំ ក្រវីក្បាលហើយនិយាយទៅកាន់ពន្លកថា៖

**ពន្លឺ ៖** ហ្នឹងហើយ មិនដឹងស្អីវាទេ!! បងមិនចង់ប្រើពាក្យមិនសមរម្យកាត់ព្រឹកព្រលឹមបែបនេះទេ ខ្លាចនាំអពមង្គលចូលផ្ទះ

ប៉ុន្តែវាហាក់បីដូចជាពេកទៅហើយណា ពន្លក។ បើពន្លកនៅតែបន្តចឹងទៀត ជីវិតដើរមិនទាន់គេ គេឡើងចេញដំណើរទៅភ្នំពេញហើយ ឯងទើបតែ មិនទាន់ងើបពីដំណេកផងហ្នឹង។ ចេះតែរស់នឹង គេកើតដែរ។

បន្ទាប់ពីបានទេសនាដាក់ពន្លករួចរាល់ ពន្លឺក៏ដក ង្ហើម ក្រវីក្បាលដើរចេញពីបន្ទប់គេង ហើយក៏ចេញទៅក្រៅ ដើម្បីស្រូបយកខ្យល់អាកាសបរិសុទ្ធនៅពេលព្រឹក មើល ទេសភាពដ៏គយគន់ ឃើញខ្យល់បក់ផាយផាត់ មកប៉ះខ្លួន ប្រាណពន្លឺហើយ ពន្លឺក៏រងាអង្អែលខ្លួនប្រាណ។ ដោយ អាកាសធាតុត្រជាក់បែបនេះពន្លឺ មិនបង្អង់យូរក៏ទៅ ស្ទុះស្ទារកជុំឈើ អូស ធ្យូង ដែកកេះ មកបង្កាត់ភ្លើង ដាំទឹក អោយច្រើនកំសៀវ ដើម្បី ទុកលាយជាមួយទឹកត្រជាក់ក្នុង ពាងដើម្បីទុកងូតផង កំសៀវខ្លះទៀតទុកដាំផឹក។

ពូលាភចុះមកពីលើផ្ទះហើយក៏ឆ្ងល់ដោយឃើញតែពន្លឺនៅធ្វើកិច្ចការនៅក្រោមផ្ទះតែម្នាក់ឯងហើយក៏សួរទៅកាន់ពន្លឺថា៖

**ពូលាភ ៖** កូនពន្លឺ

**ពន្លឺ ៖** បាទ! លោកពុក

**ពូលាភ ៖** និយាយចឹង បាត់ពន្លកទៅណាហើយអត់ឃើញវាចុះមកចឹងកុំថាវា...

(ពន្លឺឆ្លើយកាត់ពាក្យលោកពុក)

**ពន្លឺ ៖** បាទ ហ្នឹងហើយលោកពុក ពន្លកវានៅគេងមិនទាន់ងើបនៅឡើយនោះទេ កូនហៅវាប៉ុន្មានដងហើយតែវាថាចាំបន្តិចទៀតរហូត ចង់ចូលប្រហែលជាកន្លះម៉ោងហើយ គិតទៅកែមិនឡើងទេមើលទៅ ពុកជួយទៅមើលវា បន្តិចទៅ ក្រែងវាងើប។

**ពូលាភ ៖** ចំមែនកូននេះ ពិបាកនិយាយគ្នាម៉េសអីក៏បាន កូនពន្លឺងូតទឹកហើយទៅជួយមើលខុសត្រូវ មុខផ្ទះ ក្រោយផ្ទះ កុំភ្លេចជួយដាក់ចំណើមាន់ ទាជ្រូក ព្រាប

នៅក្រោយផ្ទះផងដាក់ទឹកអោយពួកវាផងនិងស្រោច ដំណាំខ្លះផង លោកពុកស្រោចខ្លះៗដែរហើយ។ លោកពុក ទៅមើលវាបន្តិចសិន។

**ពន្លឺ ៖** បាទ លោកពុក

បន្ទាប់ពីបាននិយាយជាមួយពន្លឺរួច ពន្លឺក៏ចាប់ផ្ដើមធ្វើនូវអ្វីដែលពូលាភប្រាប់ ហើយពូលាភ ក៏ឡើងទៅលើផ្ទះដោយនៅនឹងដៃមានទម្ពក់ខោអាវផង។ ពូលាភធ្វើដំណើរឆ្ពោះទៅរកកន្លែងពន្លកគេងហើយក៏ឃើញពន្លកកំពុងតែគេងស្រមុកយ៉ាងលក់ស្កប់ស្កល់។ ពូលាភក៏កើតអារម្មណ៍ក្ដៅដូចបាយពុះទាំងព្រឹក ហើយក៏...

ផាច់ ផាច់ ផាច់ !!!

**ពន្លក ៖** អួយ !!! ស្អីហ្នឹង?

ពេលពន្លកបើកភ្នែកភ្លាម ក៏ស្វាងតែម្ដងគេឃើញលោកពុកដាក់ពន្លកនឹង ទម្ពក់ខោអាវ លឺសូរតែផាច់ៗហើយក៏...

**ពន្លក ៖** លោកពុកសោះ !

**ពូលាភ ៖** មិចបានហែងធ្វើចឹងទៀតហើយ? ថ្ងៃរះឡើងចាំងគូទមិចមិនងើបទៅជួយ មើលនេះ មើលនោះចឹង ពន្លឺគ្នាដាស់ហែងហើយមិចមិនងើប ហើយក៏ស្ពឹកខ្លួនប្រាណម៉េសហាស ! អាយុច្រើន ហើយនៅអោយគេតាមប្រដៅអីទៀត នាំអញក្ដៅ កាត់ព្រឹក មិនដឹង សុភមង្គលចូលតាមណាទេ វើយ ! បើចេញមកកូនបែបហ្នឹង...

**ពន្លក ៖** ពុក! ទៅកូនងើបហើយ រអ៊ូនោះរអ៊ូ ធុញណាស់ !

**ពូលាភ ៖** យី! តមាត់អញ អញអត់មិនបានឥឡូវ ហើយអញ។

ពន្លកងើបពីគ្រែហើយរៀបចំពូកហើយចុះក្រោមងូត ទឹកផ្លាស់ប្ដូរសម្លៀកបំពាក់ទៅរៀន។ ពេលនោះអាហារ ពេលព្រឹកក៏ត្រូវបានរៀបចំរួចជាស្រេចដោយស្នាដៃកូនបង ពន្លឺមានដូចជា៖ ត្រីងៀត ពងទាប្រៃ២គ្រាប់ ទឹកតែដ៏មាន ក្លិនឈ្ងុយ និង បបរ។

អ្នកទាំងអស់គ្នានៅក្នុងគ្រួសារក៏នាំគ្នាអង្គុយស្រស់ស្រូប អាហារពេលព្រឹក។ ខណៈពេលដែលកំពុងនាំគ្នាស្រស់ស្រូប អាហារពេលព្រឹកសុខៗ ទ្រនិចនាឡិកាកំពុងដើរតុកតាក់ៗ បើមើលម៉ោងគឺម៉ោង៧កន្លះព្រឹកទៅហើយពន្លកឃើញ ដូច្នោះក៏រៀបដំណើរទៅរៀនយ៉ាងរហ័ស...

ពូលាភក៏បង្អាក់ដំណើររបស់ពន្លកហើយសួរទៅ ពន្លកថា៖

**ពូលាភ ៖** ពន្លក! ឥឡូវបាត់ការគោរពចាស់ទុំទៅ ណាអស់ហើយ? ឥឡូវលែងស្គាល់ចាស់ស្គាល់ទុំ គោរពចាស់ទុំ អ្នកមានគុណហើយមែន?

**ពន្លក ៖** ពុក! និយាយច្រើនណាស់ ខ្ញុំប្រញាប់ទៅរៀនទៅសូត្រគ្រូស្តីបន្ទោសអោយខ្ញុំឥឡូវហើយ។

**ពូលាភ ៖** បើដឹងខ្លួនហើយ លើកក្រោយងើបអោយលឿន ចេះធ្វើកាលវិភាគ ចែកតួនាទី ខ្លួនឯងមិនបាច់មើលទៅណាឆ្ងាយទេ មើលតែបងហែងខ្លះទៅ បងប្អូនអីក៏ខុសគ្នាម៉េស មួយផ្ទះចេញមកខុសគេតែឯង។ មនុស្សដូចជា ពន្លកឯងមិនដឹងពេលណាកែកើតនោះទេ។

បន្ទាប់ពីពូលាភប្រដៅ ពន្លករួចហើយពន្លកក៏យកសោរម៉ូតូពូលាភជិះទៅវិទ្យាល័យបាត់ទៅ។ ចម្ងាយពីផ្ទះពូលាភទៅវិទ្យាល័យដែលពន្លករៀនមានចម្ងាយ៥គីឡូម៉ែត្រ។

ត្រូវមាត់ទៀត

ហើយ

អាពន្ទុកអើយ!

ពន្លក បានមកដល់វិទ្យាល័យដែលខ្លួនរៀននៅម៉ោង ៨គត់។ បើមើលទៅទិដ្ឋភាពបរិវេណនៃវិទ្យាល័យដែលពន្លករៀននោះមានសភាពស្ងាត់ក៏ព្រោះដោយសារគេចូលរៀនអស់ហើយ។ ប៉ុន្តែនៅបរិវេណវិទ្យាល័យមានពូសន្តិសុខដែលមើលការខុសត្រូវវិទ្យាល័យចំនួន៣នាក់នៅទីនោះ។ ពូសន្តិសុខបានឃើញពន្លកឈប់ម៉ូតូនៅមុខរបងវិទ្យាល័យ ហើយក៏សួរទៅកាន់ពន្លកថា៖

**ពូសន្តិសុខ** ៖ ហើយគេចូលរៀនម៉ោង៧គ្រប់គ្នាហើយឯង ទើបមកដល់ហេតុអ្វីបានជាឯងមករៀនយឺតម៉េស?

**ពន្លក** ៖ ពូសន្តិសុខឯងកុំសួរនាំដេញដោលខ្ញុំច្រើនពេកបានអត់ ខ្ញុំធុញណាស់! ទម្រាំតែនិយាយឆ្លើយឆ្លងពូសន្តិសុខឯងហ្នឹងគេជិតចេញលេងទៀតទៅហើយ។

**ពូសន្តិសុខ** ៖ យើងអនុគ្រោះអោយចុះ តែហាមដាច់ខាតអត់មានករណីបែបហ្នឹងតទៀតទេណា

យើងជាសិស្សគប្បីស្គាល់នូវវិន័យនិងតួនាទីរបស់ខ្លួនកាតព្វកិច្ចរបស់ខ្លួន។

កូននរណាគេ ចេញមកចឹងអី?

**ពន្លក ៖** បាទពូ

(ឆ្លើយតបដោយទឹកមុខធុញទ្រាន់ )

ពូសន្តិសុខ ក៏កឹបសំបុត្រម៉ូតូហើយ ចង្អុលទីតាំងចតម៉ូតូ បន្ទាប់មកពន្លកក៏រត់ទៅរកអគារ និងថ្នាក់ដែលខ្លួនរៀន។ នៅពេលដែលទៅអគារនិងជាន់ដែលខ្លួនរៀន ពន្លកឃើញលោកគ្រូ ធារិទ្ធកំពុងសរសេរមេរៀននៅលើក្តារខៀនតាមបង្អួច ថ្នាក់រៀន។ ពន្លកមានភាពស្ទាក់ស្ទើរពីព្រោះពន្លកមិនហ៊ានចូលថ្នាក់នោះឡើយពីព្រោះខ្លាចលោកគ្រូធារិទ្ធ ស្តីបន្ទោស។ ភ្លាមៗនោះ ពន្លកឃើញមិត្តរបស់ខ្លួនកុសលកំពុងលេងហ្គេម។ ពេលនោះពន្លកក៏ហៅកុសលទាំងខ្សឹបៗថា៖

**ពន្លក ៖** អែ ! កុសល កុសល កុសល ...

កុសលឃើញពន្លកនៅក្រៅថ្នាក់ក៏ចាប់ផ្ដើមភ្ញាក់ហើយសួរទៅកាន់ពន្លកថា៖

**កុសល ៖** នែ ពន្លក ហើយឯងទើបមកពីណា ម៉ោង៨ហើយទើបមកដល់ ?

**ពន្លក ៖** ហែង កុំទ្រឹស្ដីនិយាយច្រើនពេកមើល អស់ពីមួយចូលមួយឥឡូវហែងជួយអញសិនមក បានអត់ ?

**កុសល ៖** ហើយតើមានរឿងអីទៅ ?

**ពន្លក ៖** អញចង់ចូលថ្នាក់ តែអញខ្លាចគ្រូស្ដី បន្ទោសខ្លាចគ្រូដឹង។

**កុសល ៖** ហែងចូលមកក្នុងថ្នាក់អោយលឿនមក គ្រូអត់ដឹងទេ លោកគ្រូធារិទ្ធ កំពុងតែ កត់មេរៀន លើក្ដារខៀន។

**ពន្លក ៖** អត់កើតទេដឹង ?

**កុសល ៖** ហែងកុំនេះ បើអញថាអោយចូល ចូលមក តែហែង តាប៉ែច្រើនពេកចឹង លោកគ្រូជារិទ្ធ ងាកមុខទាន់ ត្រូវមាត់ ឥឡូវហើយ។

**ពន្លក ៖** តែអញ...

**កុសល ៖** អញមិនដឹងទេ អត់ចេះស្តាប់គ្នា រឿងហែងទេអញនិយាយមិនស្តាប់ផង។

ពន្លកមិនរងចាំយូរ ក៏ឈានជើងដើរចូលថ្នាក់រៀនរបស់ខ្លួនទម្រង់ទិសទៅរកតុដែលខ្លួនអង្គុយពន្លកពុំទាន់ទៅដល់កន្លែងអង្គុយស្រួលបួលផងក៏ស្រាប់តែ

ពន្លកឈប់សិន !!

សម្លេងលោកគ្រូ ជារិទ្ធ បានបន្លឺឡើងអោយពន្លកឈប់ហើយសួរនាំទៅកាន់ពន្លកថា៖

**លោកគ្រូជារិទ្ធ ៖** លោកគ្រូសួរបន្តិច

**ពន្លក ៖** ត្រូវមាត់ទៀតហើយ អាពន្លកអើយ ! បាទលោកគ្រូ

**លោកគ្រូជារិទ្ធ ៖** ឯងទើបមកពីមកណា?

**ពន្លក ៖** លោកគ្រូ ខ្ញុំ ខ្ញុំ ខ្ញុំ ទើបមកពីផ្ទះ ដោយសារតែផ្លូវនៅ ក្នុងភូមិវា ...

**លោកគ្រូជារិទ្ធ ៖** បានហើយ កុំរកហេតុផល លោកគ្រូធ្វើជាគ្រូបង្រៀនរាប់ឆ្នាំហើយ លោកគ្រូដឹងពីសិស្សលោកគ្រូច្បាស់ហើយ។

**ពន្លក ៖** តែលោកគ្រូ លើកនេះវា....

**លោកគ្រូជារិទ្ធ ៖** ឈប់តមាត់ ហើយចូលទៅកន្លែងអង្គុយលើកសៀវភៅកត់មេរៀនអោយលឿនបំផុត តិចទៀត លោកគ្រូលុបមេរៀនសរសេរមេរៀនថ្មីចូលឥឡូវហើយ។ លើកក្រោយកុំធ្វើចឹងទៀតលឺនៅ?

**ពន្លក ៖** បាទ លោកគ្រូ។

ពន្លក ក៏បានដើរចូលទៅកន្លែងអង្គុយ ហើយខ្សឹបខ្សៀវថាអោយកុសលបណ្តើរកត់មេរៀនបណ្តើររហូតដល់លោកគ្រូជារិទ្ធ គោះបន្ទាត់ឈើនៅនឹងតុអោយស្ងាត់។ សិស្សានុសិស្សទាំងអស់ក៏ភ្ញាក់ហើយកុសល និង ពន្លកនាំគ្នាបិទមាត់កត់ មេរៀនបន្ត។ ពន្លករអ៊ូក្នុងចិត្តបណ្តើរ កត់មេរៀនបណ្តើរថា ៖ អញថាមែនៗ!! ច្បាស់ណាស់ថាជាថ្ងៃស៊យរបស់អញ។

# បាត់អាពន្ទក
# ទៅណាវ?

នៅម៉ោង ១១ ព្រឹក ជួងនៅវិទ្យាល័យចាប់ផ្ដើមបន្លឺឡើង គ្រូៗ និង សិស្សានុសិស្សដទៃទៀតក៏នាំគ្នារៀបចំសម្ភាររៀនសូត្រដាក់ចូលក្នុងកាតាបរៀងៗខ្លួន ជម្រាបលាលោកគ្រូ អ្នកគ្រូមុនពេលពួកគាត់ចេញទៅ សិស្សានុសិស្សខ្លះទៀត លុបក្ដារខៀនអោយលោកគ្រូ អ្នកគ្រូពេលពួកគាត់ចេញទៅ។ លោកគ្រូជារិទ្ធក៏ដូច្នោះដែរ តែមុនពេលគាត់ត្រៀមនឹងចាកចេញពីថ្នាក់រៀនរបស់គាត់ គាត់បានដាក់កិច្ចការស្រាវជ្រាវអោយសិស្សានុសិស្សទាំងអស់ស្រាវជ្រាវដើម្បីឡើងធ្វើបទបង្ហាញនៅព្រឹកស្អែក គាត់នឹងហៅឈ្មោះសិស្សណាម្នាក់ក្នុងចំណោមសិស្សានុសិស្សទាំងអស់អោយឡើងមកធ្វើបទបង្ហាញ។ កិច្ចការដែលគាត់អោយសិស្សានុសិស្សទាំងអស់ស្រាវជ្រាវនោះទាក់ទងទៅនឹងធនធានមនុស្សដោយប្រធានបទដែលទាក់ទងទៅនឹងធនធានមនុស្សនោះគឺ ៖ **ក្នុងនាមយើងជាសសរទ្រូងនៃប្រទេសជាតិនៅថ្ងៃមុខ តើយើងត្រូវបំពេញតួនាទី ឬកាតព្វកិច្ចអ្វីខ្លះដើម្បីក្លាយខ្លួនជាធនធានមនុស្សរបស់ប្រទេសជាតិ?**

បន្ទាប់ពីលោកគ្រូជារិទ្ធបានដាក់កិច្ចការស្រាវជ្រាវរួចរាល់ គាត់ក៏បានចេញពីថ្នាក់បាត់ទៅ ចំណែកសិស្សានុសិស្សដទៃក៏នាំគ្នាចេញទៅផ្ទះរៀងៗខ្លួនបាត់អស់ទៅ។

មេឃរសៀលឥឡូវហើយ ម៉ោងក៏ខិតជិតចូលម៉ោង១ទៅទៀតអត់ឃើញពន្លកមកដល់ផ្ទះនៅឡើយ ពូលាភក៏កើតក្តីបារម្ភដល់កូនពន្លកជាខ្លាំងថា ៖

**ពូលាភ** ៖ ម៉ោងជិត១ហើយ បាត់អាពន្លកទៅណាវា? ក្រែងវារាល់ដងចេញពីរៀនម៉ោង១១ ...

ពន្លឺក៏ឃើញលោកពុករបស់ខ្លួនឈរនៅរបងផ្ទះក៏ដើរទៅសួរលោកពុកថា ៖

**ពន្លឺ** ៖ លោកពុក តើលោកពុកអត់ទាន់អញ្ជើញទៅហូបបាយថ្ងៃទេ? ជិតដល់ម៉ោងលោកពុកទៅធ្វើការឥឡូវហើយ តើលោកពុកកំពុងរងចាំមើលនរណាគេដែរ?

**ពូលាភ** ៖ លោកពុកកំពុងធ្វល់ និង រង់ចាំថាអាពន្លកវាទៅណាៗវា ម៉ោងជិត១ហើយអត់ទាន់ឃើញវាមកដល់ផ្ទះ។

ពន្លឺក៏ភ្ញាក់ពេលដែលលឺពូលាភថា បាត់ប្អូនរបស់ខ្លួនមិនទាន់មកដល់ផ្ទះ។

ខណៈពេលនោះ ពូលាភក៏ឃើញក្មេងសិស្សវិទ្យាល័យមួយក្រុមកំពុងជិះម៉ូតូកាត់ផ្ទះពូលាភ គាត់ក៏បង្អាក់ពួកគាត់ហើយសួរទៅកាន់ពួកគាត់ថា ៖

**ពូលាភ** ៖ នែ ក្មួយៗ ពូសុំសួរមួយបានអត់?

ក្រុមសិស្សានុសិស្សក៏ឆ្លើយព្រមគ្នាទៅព្រមគ្នាទៅពូលាភថា ៖

ជម្រាបសួរពូលាភ តើលោកពូមានការអ្វីដែរហាក់បីដូចជាបារម្ភដូច្នោះ?

**ពូលាភ** ៖ ហ្នឹងហើយ!! ពូឆ្ងល់ថាអាពន្លកវាទៅណាវាម៉ោងជិត១អត់ទាន់ឃើញវាមកដល់ផ្ទះ តើពួកក្មួយមានប្រទះវាអត់?

ក្រុមសិស្សានុសិស្សក៏មើលមុខគ្នាទៅវិញទៅមក ទាំងទឹកមុខគិតថាតើមិត្តរបស់ខ្លួនបាត់ទៅណា ពេលនោះក្នុងចំណោមពួកគេមានម្នាក់ឆ្លើយប្រាប់គាត់ទាំងទឹកមុខច្បាស់លាស់ថា ៖

ពូ!!!!!! ខ្ញុំចាំថាមុនពេលវាចេញពីថ្នាក់រៀន ខ្ញុំលឺវានិយាយជាមួយមិត្តភក្តិគ្នាវាថា ពេលចេញពីរៀននាំគ្នាទៅហាងកាហ្វេនៅមុំវិទ្យាល័យ តែខ្ញុំអត់ដឹងថាវាទៅធ្វើអ្វីនោះទេ មិចម៉ាលោកពូជួយទៅមើលវាផង វានៅសាលាក៏មិនស្តាប់គ្រូពន្យល់ផ្តោតការរៀនសូត្រ ហើយវាដើរជាមួយពួកដែលមិនរៀនសូត្របែមទៀតផង។

ពូលាភក៏កើតក្ដីបារម្ភកាន់តែខ្លាំងឡើងឃើញសភាព បែបនោះគាត់ក៏មិនបង្អង់យូរក៏ខ្ចីម៉ូតូសិស្សម្នាក់ជិះទៅរក ពន្លក តែពន្លឺបានឃាត់លោកពុករបស់ខ្លួនថាកុំអោយទៅ ម្នាក់ឯង តែពូលាភតបទៅពន្លឺទាំងក្ដីបារម្ភនិងខឹងផងថា ៖

**ពូលាភ** ៖ នៅចាំផ្ទះហ្នឹងទៅ!!
ពុកទៅតែឯងបានហើយ។

ពូលាភក៏ចេញតម្រង់ទៅវិទ្យាល័យដែលពន្លករៀន ហើយជិះត្រឹកៗតាមផ្លៀងមើលរកពន្លក ... មិនយូរប៉ុន្មាន ពូលាភក៏ប្រទះឃើញពន្លកនិងក្រុមពួកម៉ាករបស់គេកំពុង តែណាត់ជួបគ្នាលេងហ្គេម ណាមួយពន្លកអត់មានទូរស័ព្ទ ប្រើនឹងគេផងហេតុអ្វីបានជាទៅនឹងគេដែរ? ពូលាភអត់មិន បានក៏ឈប់ម៉ូតូនៅមុខហាង កាហ្វេហើយឆ្ពោះទៅតុពន្លក ហើយក៏ហៅពន្លកថា ៖

**ពូលាភ** ៖ ពន្លក!!!!!! មិចបានជាឯង មកនៅទីនេះ និង អត់ទៅផ្ទះទៅសម្បែងចឹង ពុកនិងបងឯងតាមចាំមើលផ្លូវឡើងយូរ

មោះទៅផ្ទះវិញអោយឆាប់អោយលឿន!!!!!
ពួកក្មួយៗឯងក៏ចឹងដែរ មិនគិតទៅផ្ទះទៅ សម្បែងចឹង មិចបាននាំគ្នាណាត់ជួបហ្នឹងចឹង អ្នកផ្ទះពួកក្មួយៗឯងក៏រងចាំដែរទៅ ទៅ ទៅ ...

**ពន្លក ៖** ពុក!!!! អត់អោយខ្ញុំលំហែខួរក្បាលខ្លះទេអី?

**ពូលាភ ៖** មើលវានិយាយដាក់ពុកវា ហែងចេះមកពីណាបាននិយាយ អីចឹង? គ្មានគ្រូបាអាចារ្យព្រះឥន្ទ្រណាបង្រៀនហែងចឹងទេ មោះទៅផ្ទះម៉ូតូខ្ចីមិត្តរួមថ្នាក់ហែងផង និយាយគ្នានៅផ្ទះ។

ពូលាភ និង ពន្លកក៏ចេញទៅផ្ទះរបស់ខ្លួន ពេលទៅដល់មុខផ្ទះពូលាភក៏បានប្រគល់ម៉ូតូជូនសិស្សថ្នាក់ពន្លកវិញថា ៖

**ពូលាភ ៖** អោយពូសុំទោសផងក្មួយណា ពូខ្ចីយូរបន្តិចមិចហ្នឹងដោយសារនៅប្រដៅពន្លកក្មួយៗជួយតាមដានវាផង មិចម៉ាចាំប្រាប់ពូ។

**ក្រុមសិស្សានុសិស្ស ៖** បាទចាសលោក
ពូលាភ! មិនអីនោះទេ ចាំខ្ញុំតាមដានពន្លកអោយ
ដោយសារមនុស្សដូចជាពន្លកពិបាកនិយាយគ្នា
ណាស់ អត់ខំប្រឹងរៀននោះទេទេមិនអីទេពួកខ្ញុំ
នឹងតាមដានពន្លកនូវរាល់សកម្មភាពរបស់
ពន្លក។

**ពូលាភ ៖** បាទពូអរគុណច្រើនហើយ!!! ទៅផ្ទះ
ចុះ ប្រហែលជាពុកម្ដាយក្មួយប្រាកដជាបារម្ភ
ហើយ។

**ក្រុមសិស្សានុសិស្ស ៖** បាទ ចាស លោកពូ
លាភមិនអីនោះទេ ចឹងពួកខ្ញុំលាទៅសិនហើយ។

**ពូលាភ ៖** បាទ! សុខសប្បាយក្មួយៗជិះ
អោយស្រួលបួលប្រយ័ត្នប្រយែងផង។

បន្ទាប់ពីក្រុមសិស្សានុសិស្សចេញទៅបាត់ទៅ
ពូលាភក៏ចោលភ្នែកសម្លឹកដាក់ពន្លក និយាយទាំង
អារម្មណ៏ក្ដៅក្រហាយថា ៖

**ពូលាភ ៖** មិចបានជាឯងទៅរាប់រកជាមួយពួកក្រុមមនុស្សដូចជាពួកវាចឹងវាមានប្រយោជន៍ណាស់ទៅមែនឬ? ប្រាប់ភ្លាម!!!!!

**ពន្លក ៖** ពុក!! វាជារឿងរបស់ខ្ញុំទេ កុំមកចង់ដឹង ចង់លឺពេកបានអត់? ខ្ញុំធំហើយពុក។

**ពូលាភ ៖** ដឹងថាពុកបារម្ភអត់ ទៅណាមកណាអត់ប្រាប់ពុកមុនណាមួយមិត្តរួមថ្នាក់ឯងថាឯងរៀនអត់ពូកែទៀត អត់យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ទៀត ហើយមិចបានទៅជាចឹងទៅវិញ? (ពូលាភនិយាយទាំងអារម្មណ៍ក្តុកក្តួល ចង់ហូរទឹកភ្នែក) ពុកខំដើម្បីកូនពន្លកឯងច្រើនណាស់។ តើកូនពន្លកមាននឹក ឬក៏ដឹងខ្លះអត់? ពុកមិនចង់ឃើញកូនពន្លកបែបហ្នឹងរហូតតទៅមុខនោះទេ យកគម្រូតាមបងខ្លះទៅ។

ខណៈពេលដែលពូលាភកាន់ដៃកូនគាត់ ស្រាប់តែពន្លកដកដៃពូលាភចេញ និយាយទៅកាន់ពូលាភថា ៖

**ពន្លក** ៖ មិនដឹងជាស្អីទេ !!! បានឈប់ ខ្ញុំឃ្លានបាយណាស់ ឯណាបាយ? ខ្ញុំទៅរកបាយហើយ។

**ពន្លឺ** ៖ ឈប់ អាពន្លក!!! ហែងធ្វើនេះមានដឹងថាខុសធ្ងន់ធ្ងរបាបនៅមុខពុកហែងអត់ហាក!? អញអត់អោយបាយហែងទេ ហែងទាល់តែមកសុំទោសលោកពុកសិនមនុស្សអីចឹងរៀនធំតែថ្នាក់តែចំណេះដឹងរស់នៅការប្រើប្រាស់ពាក្យសម្តីសូន្យបាតថ្នាក់ម៉ង ជាងហ្នឹងទៀត ហែងមកអោយឆាប់!!!!

**ពន្លក** ៖ មិនដឹងជាស្អីទេមួយៗ!! ដូចម៉េសៗបានហើយខ្ញុំចេញពីទីនេះហើយធុញណាស់!!

មិនយូរប៉ុន្មាន ពន្លកក៏ស្ពាយកាតាបចេញពីផ្ទះ មិនដឹងថាខ្លួនទៅណានោះទេពូលាភក៏ព្យាយាមធ្វើយ៉ាងណានិយាយបែបណាក៏ពន្លកមិនខ្វីងាកក្រោយនោះទេ។ ពន្លឺក៏អោបពូលាភទាំងពូលាភកំពុងតែយំ ពន្លឺក៏ប្រាប់ពូលាភថា ៖

**ពន្លឺ** ៖ កុំយំកុំខឹងលោកពុក លោកពុកចាស់ហើយ លោកពុកមិនគួរយំនិងខឹងនោះទេប្រយ័ត្នសុខភាពធ្លាក់ចុះ។

**ពូលាភ** ៖ តែពុកបារម្ភពីវាណាស់ខ្លាចវាប្រព្រឹត្តឬដើរវិថីខុស។

**ពន្លឺ** ៖ នេះគ្រាន់តែជាអារម្មណ៍មួយភ្លែតរបស់វាទេតែតិចទៀតវានឹងត្រឡប់មកវិញហើយពេលវាដឹងខ្លួនថាវាមានកំហុសយ៉ាងណានោះ។

ពន្លឺក៏នាំពូលាភទៅក្នុងផ្ទះហូបអាហារពេលថ្ងៃត្រង់ និង ចេញទៅធ្វើការសំណង់បាត់ទៅ។

. . . . . លុះដល់ព្រះសុរិយារៀបអស្តង្គតបន្តិចម្តងៗ មេឃក៏ចាប់ផ្តើមងងឹតទៅៗនៅតាមផ្ទះក្នុងភូមិនីមួយៗក៏នាំគ្នាបើកភ្លើងបំភ្លឺរៀងៗខ្លួន។ ម៉ោង ៦:៣០ នាទីល្ងាច ពូលាភក៏ចេញពីធ្វើការសំណង់ល្មម ពូលាភក៏ហៅពន្លឺដោយសារនៅផ្ទះងងឹតឈឹងថា៖

**ពូលាភ** ៖ កូនពន្លឺ កូនពន្លឺ អឺកូនពន្លឺ !

**ពន្លឺ** ៖ បាទលោកពុក

**ពូលាភ** ៖ មិចបានជាផ្ទះងងឹតឈឹងចឹងកូន ?

**ពន្លឺ** ៖ អូ អោយកូនសុំទោសលោកពុកដោយសារកូននៅរៀបចំធ្វើ ម្ហូបហ្នឹងណា កូនក៏ភ្លេចពិនិត្យមើលជុំវិញផ្ទះទៅ។ លោកពុកអង្គុយសម្រាកសិនចុះ លោកពុកប្រាកដជាហត់ហើយចាំតិចទៀតលោកពុកទៅងូតទឹកទៅចាំមកហូបអាហារពេលល្ងាចជុំគ្នា។

នៅពេលដែលពន្លឺកំពុងរៀបចំធ្វើម្ហូបអាហារពេល
ល្ងាចអោយពូលាភពូលាភដើរចុះដើរឡើងជុំវិញផ្ទះ
ហាក់បីដូចជាកំពុងតែរកកូនប្អូនរបស់គាត់ពន្លក។

អស់រយៈពេលមិនយូរប៉ុន្មាននោះ ពន្លឺក៏រៀបចំធ្វើម្ហូបអាហារពេលល្ងាចរួចជាស្រេច ភ្លាមៗនោះពន្លឺក៏មានអារម្មណ៍ថា បាត់លោកពុករបស់ខ្លួនទៅណា បែរជាគ្មានសម្លេងស្ងាត់ដូច្នោះ។ ពន្លឺតាមរកលោកពុករបស់ខ្លួនមិនយូរប៉ុន្មានពន្លឺក៏ប្រទះលោកពុកគាត់កំពុងតែអង្គុយនៅក្រោយផ្ទះទឹកមុខហាក់បីដូចជានឹកកូនពន្លកជាខ្លាំងពីព្រោះពូលាភអត់ឃើញកូនរបស់ខ្លួនមកផ្ទះនោះទេ។ ពូលាភកើតក្តីបារម្ភកាន់តែខ្លាំងឡើងៗពេលអត់ឃើញកូនរបស់ខ្លួនមកផ្ទះ ពេលនោះពន្លឺក៏ប្រាប់ទៅកាន់លោកពុករបស់ខ្លួនថា ៖

**ពន្លឺ** ៖ លោកពុក ពន្លកអត់ទាន់មកផ្ទះវិញនោះទេ កូនក៏មិនដឹងថាវាទៅណាបាត់ទេ កូនក៏បានសួរអ្នកនៅក្នុងភូមិផងដែរ តែពួកគាត់បានប្រាប់ថាអត់បានប្រទះវានោះទេ ។ កុំបារម្ភអីលោកពុក វាមិននៅឆ្ងាយពីទីនេះនោះទេ ពេលខ្លះវាចង់នៅម្នាក់ឯង វាអាចនឹងយកពេលវេលាគិតគូរនូវអ្វីដែលវាបានប្រព្រឹត្ត តែនេះវានឹងមកវិញហើយ។

**ពូលាភ** ៖ តែកូន ... ពុកពិតជាបារម្ភពីវាខ្លាំងជាងកូនទៅទៀតលោកពុកមិនចង់អោយគ្រួសារនេះខូចឈ្មោះដោយសារតែពន្លកនោះទេពុកខ្លាចណាស់ លោកពុកក៏ខំប្រឹងអស់ពីសមត្ថភាពទៅហើយ តែលោកពុកនៅតែមិនអស់សង្ឃឹមចំពោះកូនទាំងពីរដែរ។ លោកពុកមានតែពីរនាក់បងប្អូននេះតែប៉ុណ្ណោះលោកពុកមិនដែលគិតថាទុកមួយណាចោលមួយណានោះទេ។

លោកពុកស្រលាញ់ពួកកូនទាំងពីរស្មើៗគ្នា ទោះបីជាយ៉ាងណាក៏ដោយ លោកពុកនៅតែបន្ដជានិច្ចដើម្បីកូនទាំងពីររបស់ពុកដែលប្រៀបបានដូចជាដុំពេជ្រ។

(និយាយទាំងអារម្មណ៍ក្ដុកក្ដួលក្នុងចិត្ត)

**ពន្លឺ** ៖ បាទលោកពុក ! កូនយល់ពីអ្វីដែលលោកពុកបានមានប្រសាសន៍ ទំហំនៃសេចក្ដីស្រលាញ់ការលះបង់របស់លោកពុកកូនក៏យល់ដូចគ្នា កូនក៏សូមអរគុណដល់លោកពុកដែលបានចិញ្ចឹមបីបាច់ថែរក្សាកូន បានបង្ហាត់បង្រៀនកូនពីមុនមក កូនពិតជាសំណាងណាស់ដែលកើតមកជាកូនប្រុសរបស់លោកពុក។ កូននិងលោកពុកក៏មិនអស់សង្ឃឹមដូចគ្នា កូនក៏សង្ឃឹមថាជីវិតគ្រួសារមួយនេះនឹងល្អជានេះផងចុះ។

ដូច្នេះលោកពុកសូមទៅងូតទឹកសិនទៅលោកពុក កូនបានរៀបចំម្ហូបអាហារដែលលោកពុកចូលចិត្តច្រើនមុខណាស់ សូមលោកពុកប្រញាប់ទៅងូតទឹក មកហូបបាយជុំគ្នា ល្ងាចនេះកូនមានសម្លស្ងោរជ្រក់ក្បាលត្រី ឆាខ្ញីសាច់មាន់ និង ប្រហុកចំហុយសុទ្ធតែម្ហូបដែលលោកពុកចូលចិត្ត។

# យប់មួយ

ក្រោយពីបានហូបបាយល្ងាចរួចរាល់ ពូលាភក៏អស់កម្លាំងពីការងារផង អារម្មណ៍នៅតែវិលវល់គិតគូរនឹកពន្លកផង ពន្លឺក៏នាំលោកពុករបស់ខ្លួនទៅលើផ្ទះនាំគាត់ទៅបន្ទប់គេងរៀបចំគ្រែ ពូក ខ្នើយ ភួយ បន្ទប់គេង អោយបានស្អាតបាត និង នាំគាត់ចូលដំណេក ដណ្តប់ភួយអោយគាត់បិទទ្វារ។ ពេលរៀបចំកន្លែងគេងនិងនាំគាត់ចូលដំណេករួចរាល់ ពន្លឺចុះមកក្រោមផ្ទះពិនិត្យខុសត្រូវផ្ទះម្តងទៀតខ្លាចមានកន្លែងខ្លះខ្វះខាត និង រៀបចំយកអាហារខ្លះដែលនៅសេសសល់យកទៅទុកក្នុងទូដាក់ម្ហូបចៀសវាងកុំអោយរុយឬស្រមោចរោម។ ចំណែកចានដែល ប្រឡាក់ៗពន្លឺក៏ប្រមូលយកទៅលាងសម្អាតផងដែរ។ ពេលដែលពន្លឺលាងចាន ពិនិត្យខុសត្រូវរួចរាល់ក៏ឡើងទៅលើផ្ទះបិទទ្វារចាក់សោរ បិទបង្អួចក្នុងបរិវេណក្រៅបន្ទប់ និង ចូលបន្ទប់គេងរបស់ខ្លួន។ ព្រះចន្ទក៏ចាប់ផ្តើម បញ្ចេញពន្លឺដ៏ស្រស់ស្អាតនាពេលយប់ គួបផ្សំជាមួយដួងតារារាប់លានកំពុងបញ្ចេញពន្លឺផងដែរ។

អាកាសធាតុនាពេលយប់ក៏ត្រជាក់ផងដែរ ណាមួយស្ថិតក្រោមរដូវធ្លាក់ខ្យល់ទៀត ដូច្នេះនៅពេលយប់អាកាសធាតុកាន់តែត្រជាក់បន្ថែមទៀត។

ពន្លឺកំពុងអង្គុយនៅតុរៀន សម្លឹងទៅព្រះចន្ទ និងដួងតារា ផ្កាយដែលកំពុងបញ្ចេញពន្លឺដ៏ស្រស់ស្អាតផង គិតចំពោះប្អូនប្រុសរបស់ខ្លួនដែលបានបាត់ដំណឹងតាំងពីពេលគេឈ្លោះជាមួយលោកពុករហូតមកទល់ពេលនេះ ថាអត់ដឹងប្អូនរបស់ខ្លួនទៅដល់ទីណានោះទេ ទោះបីជាពន្លឺសួរអ្នកភូមិផង ព្យាយាមស្វែងរកខ្លួនឯងផងក៏រកមិនឃើញទៀត។ មិនថាលោកពុករបស់ខ្លួននោះទេ សូម្បីតែពន្លឺក៏មានក្តីនឹករលឹកដល់ពន្លក និង បារម្ភពន្លកខ្លាចពន្លកសម្រេចចិត្តខ្លី ពីព្រោះពន្លកតាំងពីធំដឹងក្តីមកគ្នាអត់ដែលជួបទិដ្ឋភាពបែបនោះទេ។ យប់មួយនេះ ពន្លឺគេងមិនសូវលក់ស្កប់ស្កល់ដូចរាល់ដងនោះទេ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ ពន្លឺក៏មានការស្ទាក់ស្ទើរចំពោះការបន្តរៀននៅសាកលវិទ្យាល័យផងដែរ។

ពន្លឺគិតពិចារណាខ្លួនឯងថា ៖

**ពន្លឺ** ៖ ហឹម!! តើខ្ញុំគួររៀនបន្តនៅសាកលវិទ្យាល័យឬក៏អត់? ខ្ញុំពិត ជាអាណិតលោកពុកណាស់ លោកពុកគាត់កាន់តែអាយុច្រើននិងពីមួយថ្ងៃទៅមួយថ្ងៃកម្លាំងគាត់ក៏មិនអាចនៅបានយូរផងដែរ។ អាយុកាន់តែច្រើន កម្លាំងក៏កាន់តែចុះទៀត។ ជាពិសេសនោះគាត់ធ្វើការជាកម្មករសំណង់ដូចជា លើកបាវដីខ្សាច់ បញ្ជូនដុំឥដ្ឋ រៀបដុំឥដ្ឋ លាបថ្នាំពណ៌នៅតាមជញ្ជាំងផ្ទះទៀត។ ខ្ញុំមិនចង់ចាកឆ្ងាយពីគាត់ទេ តែខ្ញុំមិនចង់អោយគាត់បន្តភាពហត់នឿយនឹងការងារបែបនោះទេពីព្រោះការងារបែបនោះជាការងារប្រើប្រាស់កម្លាំងកាយ។ ណាមួយខ្ញុំមិនចង់អោយគាត់បន្តរកលុយចិញ្ចឹមខ្ញុំនិងពន្លកនោះទេ ខ្ញុំចង់តបស្នងរកលុយចិញ្ចឹមគាត់វិញ

នេះក៏អាចនិយាយបានថា វាជាវេនដែលខ្ញុំជាកូនបងត្រូវតែបន្តពីគាត់ពីព្រោះគាត់មិនអាចនៅបន្តចិញ្ចឹមខ្ញុំនិងពន្លកតទៅទៀតបាននោះទេគាត់ត្រូវតែសម្រាក។ វាគ្រប់គ្រាន់បាត់ទៅហើយដែលគាត់បានខិតខំព្យាយាមរកលុយអោយខ្ញុំនិងពន្លក។ ដូច្នេះខ្ញុំនឹងតបស្នង ជួយសម្រួល ចិញ្ចឹមគាត់ម្តង ខ្ញុំនឹងចិញ្ចឹមគាត់អោយរស់ដូចគាត់បានចិញ្ចឹមខ្ញុំនិងពន្លករស់តាំងពីតូចដល់ធំដឹងក្តី។ ខ្ញុំគិតថាប្រហែលមិនយូរមិនឆាប់នោះទេ ខ្ញុំនឹងរកការងារក្រៅម៉ោងនៅភ្នំពេញ និង រៀនតនៅភ្នំពេញ ពីព្រោះតាំងពីតូចមកដល់ឥឡូវអត់ដែលស្គាល់អ្នកទីក្រុងសោះ។ ខ្ញុំនឹងព្យាយាមពុះពារអោយលោកពុកនិងប្អូនប្រុសរបស់ខ្ញុំដូចលោកពុកបានចិញ្ចឹមខ្ញុំចឹង។ ខ្ញុំមិនចង់អោយគាត់ពិបាកនោះទេ។

ខ្ញុំចង់អោយគាត់សម្រាកពីការងារ មិនចង់អោយគាត់ពិបាកទ្រាំនឹងការងារប្រភេទនោះទៀតទេ ក៏ប៉ុន្តែអ្វីដែលខ្ញុំបារម្ភជាងនេះទៅទៀតគឺប្អូនប្រុសរបស់ខ្ញុំថា ចុះប្រសិនខ្ញុំចាកចេញពីគាត់និងលោកពុកទៅ តើពន្លកអាចគ្រប់គ្រងលោកពុកបានអត់ ប្រសិនបើមនុស្សដូចជាពន្លកមិនដឹងថាពេលណាកែខ្លួននោះទេ? ខ្ញុំពិតជាបារម្ភពីវាខ្លាំងណាស់។ មិនដឹងថាទៅរួចឬក៏អត់ទេ តែខ្ញុំពិតជាមិនចង់អោយលោកពុកពិបាកមែន ខ្ញុំមិនចង់អោយគាត់បន្តការងាររបស់គាត់នោះទេ។

ចឹងចុះខ្ញុំអាចនឹងសម្រេចចិត្តថា នឹងទៅរៀនបន្ត
នៅភ្នំពេញ និង រកការងារក្រៅម៉ោងនៅភ្នំពេញ
ដើម្បីសម្រួលបន្ទុកលោកពុក ក៏សង្ឃឹមថាពន្លក
នឹងកែខ្លួនផងចុះពីព្រោះខ្ញុំបានប្រឹងអស់ពី
សមត្ថភាពហើយ។

មិនយូរប៉ុន្មាននោះ ពន្លឺក៏ឈប់គិតពិចារណាបន្ត
និងរៀបចូលដំណោកតែម្តងទៅ។

# ជនជានមនុស្ស

ព្រឹកថ្ងៃស្អែកចូលមកដល់ មាន់រងាវក៏បន្លឺសម្លេងដូចរាល់សព្វដង ពន្លឺក៏ក្រោកពីដំណេក រៀបចំបន្ទប់គេង ពូកខ្នើយ ភួយ បន្ទប់គេង អោយបានស្អាតបាតដូចសព្វដង។ ពន្លឺរួសរាន់បង្កាត់ភ្លើងដើម្បីដាំទឹក ដាំបាយ ដួតទឹក និងរៀបចំធ្វើម្ហូបអាហារពេលព្រឹកអោយលោកពុក ដើម្បីអោយគាត់ទៅធ្វើការ។ ប៉ុន្តែថ្ងៃនេះហាក់បីដូចជាប្លែកជាងរាល់ដង។ រាល់ដងពន្លឺ និង ពូលាភក្រោកពីដំណេកសឹងតែទាន់គ្នាតែព្រឹកនេះពន្លឺមានអារម្មណ៍ថា ៖

**ពន្លឺ** ៖ ចុម ! ព្រឹកនេះចម្លែកម៉េស? អត់ឃើញលោកពុកចុះមកហូបបាយដូចរាល់ដង គាត់កើតអ្វីទៅ? មិនស្រួលទេដឹង ឡើងទៅបន្ទប់គាត់សិន។

នៅពេលដែលពន្លឺឡើងទៅចូលក្នុងបន្ទប់ ភ្លាមនោះក៏ស្រាប់តែ ...

ពុក !!!!

សម្លេងនេះហាក់បីដូចជា ពន្លឺបារម្ភជាខ្លាំងនោះគឺពូលាភមិនសូវស្រួលខ្លួននោះទេគាត់ហាក់បីដូចជាគ្មានកម្លាំងនៅក្នុងខ្លួននោះទេ ។ ពូលាភទន់ខ្លួន ដែលអោយពន្លឺបារម្ភជាខ្លាំង។ មិនបង្អង់យូរ ពន្លឺក៏ត្រួតពិនិត្យខុសត្រូវផ្ទះចាក់សោរផ្ទះទាំងមុខទាំងក្រោយនិងជូនគាត់ទៅមន្ទីរពេទ្យដែលនៅមិនឆ្ងាយពីផ្ទះរបស់ពូលាភនោះទេ។

….. នៅម៉ោង ៧ ព្រឹកព្រលឹម ជួងនៅវិទ្យាល័យក៏បន្លឺអោយសិស្សនាំគ្នាចូលថ្នាក់រៀនរៀងៗខ្លួន ។ ព្រឹកនេះគឺជាព្រឹកដែលលោកគ្រូធារិទ្ធហៅសិស្សមួយនាក់ក្នុចំណោមសិស្សានុសិស្សទាំងអស់មកអោយឡើងមកធ្វើបទបង្ហាញនូវកិច្ចការស្រាវជ្រាវរបស់គាត់ដែលគាត់បានដាក់កាលពីម្សិលមិញនោះគឺ៖

**ក្នុងនាមយើងជាសសរទ្រូងនៃប្រទេសជាតិនៅថ្ងៃមុខ តើយើងត្រូវបំពេញតួនាទី ឬ កាតព្វកិច្ចអ្វីខ្លះដើម្បីក្លាយខ្លួនជាធនធានមនុស្សរបស់ប្រទេសជាតិ?**

អំឡុងពេលដែលលោកគ្រូធារិទ្ធកំពុងរកចាប់ផ្តើម អោយសិស្សឡើងមកធ្វើបទបង្ហាញនូវកិច្ចការស្រាវជ្រាវរបស់គាត់ដែលគាត់បានដាក់កាលពីម្សិលមិញនោះក៏ស្រាប់តែ ...

ពន្លក !!!

សម្លេងដ៏ភ្ញាក់ផ្អើលមួយនេះបានបន្លឺពេញថ្នាក់ទាំងគ្រូទាំងសិស្សដែលពួកគាត់ទាំងអស់គ្នាបានឃើញនូវសភាពខ្លួនប្រាណរបស់ពន្លកចូលក្នុងថ្នាក់រៀនទាំងសម្លៀកបំពាក់ប្រឡាក់សុទ្ធតែដី និង សភាពខ្មៅកង្វក់ ។ ភ្លាមៗនោះលោកគ្រូធារិទ្ធក៏សួរទៅកាន់ពន្លកថា ៖

**លោកគ្រូធារិទ្ធ** ៖ ពន្លក ! តើកូនមកពីណាបានជាសភាពបែបហ្នឹង?

**ពន្លក** ៖ លោកគ្រូ ម្សិលមិញខ្ញុំបានចេញពីផ្ទះដោយសារ ខ្ញុំបានឈ្លោះជាមួយលោកពុកខ្ញុំណាមួយខ្ញុំគេងក្រៅផ្ទះទៀត។

(និយាយទាំងអោនមុខចុះ)

**លោកគ្រូធារិទ្ធ** ៖ ហេតុដូចម្តេចបានជាពន្លក ប្រព្រឹត្តរឿងដាក់គាត់ចឹង? គាត់ខំចិញ្ចឹមបីបាច់ ថែរក្សាពន្លក តាំងពីតូចមករហូតដល់វ័យមួយ នេះ វាលំបាកបែបណាទៅ? វាពិតជាលំបាក ណាស់ លោកគ្រូមិននឹកស្មានថាពន្លកប្រព្រឹត្ត រឿងបែបនេះទាល់តែសោះ។ ចូរពន្លកពេលទៅ ផ្ទះវិញរកមូលហេតុ និង សុំទោសលោកពុករបស់ ពន្លកទៅពីព្រោះពាក្យ សុំទោស វាមិនធ្ងន់ណាស់ ណានោះទេ ដូចមានមតិមួយយល់ថា ៖

**« ការស្គាល់កំហុស និង ចេះកែប្រែកំហុសរបស់ ខ្លួនធ្វើអោយមនុស្សមានតម្លៃក្នុងសង្គម»។**

សូមចូរប្អូនធ្វើតាមលោកគ្រូចុះ លោកគ្រូសង្ឃឹម ថាគាត់នឹងអភ័យទោសអោយពន្លក។ លោកគ្រូ ឃើញនូវសភាពបែបហ្នឹងដូចជា

… មិនអីនោះទេឈរនៅទីនេះចុះ លោកគ្រូទៅយកសម្លៀកបំពាក់ប្តូរជូនអោយពន្លក ដោយសារពន្លកសម្លៀកបំពាក់របស់ពន្លកប្រឡាក់។

លោកគ្រូជារិទ្ធក៏រត់ស្ទុះទៅរកសម្លៀកបំពាក់ថ្មីនៅក្នុងឡានដែលគាត់បានយកតាមខ្លួនទុកជាមុន វាក៏ជាសំណាងដែរ ដែលលោកគ្រូជារិទ្ធមានសម្លៀកបំពាក់សិស្សទុកក្នុងឡាន ទោះបីជាសាច់ក្រណាត់ចាស់បន្តិចក៏ពិតមែនតែវាគ្រាន់ជាងសម្លៀកបំពាក់របស់ពន្លកពេលនេះ។

…ពេលដែលការផ្លាស់ប្តូរសម្លៀកបំពាក់រួចរាល់ លោកគ្រូអោយពន្លកចូលកន្លែងអង្គុយនិងចាប់ហៅសិស្សឡើងមកធ្វើបទបង្ហាញនូវកិច្ចការស្រាវជ្រាវរបស់គាត់ដែលគាត់បានដាក់កាលពីម្សិលមិញ។ គាត់ក៏បានហៅសិស្សមួយនាក់ក្នុងចំណោមសិស្សានុសិស្សទាំងអស់មកបកស្រាយ សិស្សម្នាក់នោះបានបកស្រាយថា ៖

« ទោះបីជាកាលៈទេសៈណាក៏ដោយក៏កម្លាំងយុវជនជាកម្លាំងចាំបាច់ជាងកម្លាំងដទៃទៀតដែលមានក្នុងសង្គម។ កម្លាំងនេះមានសារៈប្រយោជន៍ក្នុងពេលជាតិមានវិបត្តិដោយសង្គ្រាមឈ្លានពានពីសំណាក់សត្រូវ ឬ ក្នុងគ្រាមានអាសន្នអន្ទ្រក្រ។ ស្ថិតក្នុងស្ថានភាពដ៏ចាំបាច់នោះ យុវជនជាអ្នកឈានមុខបំពេញកាតព្វកិច្ចជូនជាតិមាតុភូមខ្លួន ដើម្បីស្វែងរកភាពសុខសាន្តជូនប្រជារាស្ត្រ។ ក្រោយពីការពារជាតិ យុវជនក៏ជាអ្នកមានសមត្ថភាពក្នុងការអភិវឌ្ឍន៍ជាតិដែរ។ យុវជនពោរពេញដោយថាមពល និង មានថាមពលនៃការសិក្សាស្រាវជ្រាវ ដោយសារការលះបង់ពេលវេលាសម្រាប់ខ្លួនគឺយកចំណេះវិជ្ជា ឬ ជំនាញណាមួយដែលខ្លួនមានមកបង្កើតជាសមិទ្ធផលសង្គមជាប្រយោជន៍សាធារណៈ។ យុវជនបានលះបង់កម្លាំងកាយចិត្ត កម្លាំងស្មារតី ដើម្បីសិក្សាស្រាវជ្រាវរុករកអ្វីដែលជាតម្រូវការរបស់សង្គមជាពិសេសរបស់ប្រជារាស្ត្រខ្លួន។

ស្របតាមគោលបំណងខាងលើ អាស្រ័យយុវជនដែលជាទំពាំងស្នងឫស្សី ចេះធ្វើអោយសមត្ថភាពរបស់ខ្លួនមានការអភិវឌ្ឍន៍ពីមួយថ្ងៃទៅមួយថ្ងៃតាមរយៈការសិក្សា ក្រេបយកចំណេះវិជ្ជាដែលលោកគ្រូ អ្នកគ្រូ បង្ហាត់បង្រៀននៅសាលាយកមកអនុវត្តជាលំហាត់ប្រៀបដូចជាលំហាត់បង្វឹកខួរក្បាលដូច្នោះចឹង។ ដោយមិនត្រូវដកដង្ហើមចោល បោះបង់ពេលវេលាសម្រាប់អនាគតខ្លួននោះទៅជាការដើរលេងស៊ីចាយហ៊ឺហា ឈ្លក់វង្វេងនឹងសម្ភារនិយម ឬ ឈ្លក់វង្វេងនឹងគ្រឿងស្រវឹងឬក៏គ្រឿងញៀន។ មិនតែប៉ុណ្ណោះយុវជនក៏មិនត្រូវបង្កភាពអសកម្មដូចជា អុកឡុកក្នុងភូមិបង្ហោះម៉ូតូ ស្រែកឡូឡា បាត់បង់សណ្ដាប់ធ្នាប់ក្នុងសង្គមធក់ប្លន់ ក្លាយជាបងធំបងតូច ដើរជម្រិតគេនោះទេ។ រាល់នូវសកម្មភាពទាំងអស់នេះ មិនត្រឹមតែអោយខ្លួនបាត់បង់កិត្តិយសនោះទេ តែក៏អោយបាក់មុខមាត់លោកពុកអ្នកម្ដាយដែរ ដែលគាត់ខិតខំចិញ្ចឹមបីបាច់ថែរក្សា រកលុយអោយរៀន តែបែរមកប្រព្រឹត្តបែបនោះ។

មិនត្រឹមតែប៉ុណ្ណោះនោះទេ ពុកម្តាយខ្លះទៀតតាមដានកូនរហូតដល់សាលារៀន ដើម្បីតាមដានសួរព័ត៌មានពីមិត្តរួមថ្នាក់ លោកគ្រូអ្នកគ្រូ អំពីដំណឹង ឥរិយាបថកូនរបស់ខ្លួនក្នុងការសិក្សាដែលអោយខាតបង់ពេលវេលារកស៊ីចិញ្ចឹមជីវិតទៀត ដូច្នេះយើងត្រូវខិតខំបណ្តុះស្មារតី និង ស្គាល់ពីកាតព្វកិច្ចរបស់ខ្លួន ចេះកែប្រែខ្លួន អភិវឌ្ឍបុគ្គលិកលក្ខណៈខ្លួនអោយកាន់តែមានប្រយោជន៍ទៅថ្ងៃមុខចំពោះគ្រួសារ និង សង្គមជាតិ»។

# លោកពុក
# អោយកូន
# សុំទោស

បន្ទាប់ពីថ្នាក់លោកគ្រូធារិទ្ធត្រូវបានបញ្ចប់រួចរាល់នោះមុនពេលគាត់ចាកចេញពីថ្នាក់រៀន គាត់បានហៅពន្លកនិយាយប្រាប់ពន្លកថា ៖

**លោកគ្រូធារិទ្ធ** ៖ ចូរពន្លកកុំភ្លេចទៅសុំទោសលោកពុករបស់ពន្លកផង។ សូមកុំភ្លេចថាគុណមាតាបិតាធំធេងណាស់ គ្មានអ្វីអាចប្រៀបផ្ទឹមបាននោះទេ។

ពន្លកបានតែស្ដាប់ក៏ចេញពីថ្នាក់រៀនបាត់ទៅ លោកគ្រូធារិទ្ធគិតក្នុងចិត្តថា៖

**លោកគ្រូធារិទ្ធ** ៖ សង្ឃឹមថាពន្លកអនុវត្តតាមខ្ញុំផងចុះ។

ពូលាភក៏ភ្ញាក់ដឹងខ្លួនឡើងនៅក្នុងបន្ទប់សម្រាកនៅក្នុងមន្ទីរពេទ្យ គាត់ក៏ សម្លឹងទៅពន្លឺសួរថា ៖

**ពូលាភ** ៖ កូនពន្លឺ ម៉ោងប៉ុន្មានហើយ?

**ពន្លឺ** ៖ បាទលោកពុក ម៉ោង ២ រសៀលទៅហើយ។ យ៉ាងម៉េចហើយលោកពុកនៅក្នុងខ្លួនធូរខ្លះនៅ?

**ពូលាភ** ៖ លោកពុកមិនអីនោះទេ គ្រាន់យប់មិញលោកពុកគេងមិនសូវបាននោះទេ ចឹងបានជាលោកពុកមិនសូវស្រណុកក្នុងខ្លួនហ្នឹងណា។

**ពន្លឺ** ៖ លោកពុកសម្រាន្តមិនសូវបានដោយសារពន្លកមែនឬ?

គ្រាន់តែលឺឈ្មោះពន្លកភ្លាម ពូលាភក៏សួរទៅពន្លឺភ្លាមៗថា ៖

**ពូលាភ** ៖ និយាយចឹងយ៉ាងមិចហើយ មានបានដំណឹងពីពន្លកអត់ថា វាទៅណា?

**ពន្លឺ** ៖ អត់ទេលោកពុក មកទល់ពេលនេះពុំទាន់មានដំណឹងពីពន្លកនោះទេ។

**ពូលាភ** ៖ កូននេះ! មិនដឹងវាទៅណានោះទេ។

នៅម៉ោង ៣ រសៀល ពូលាភ និង ពន្លឺក៏មកដល់ផ្ទះ ល្មមអាការៈរបស់ពូលាភមិនជាធ្ងន់ធ្ងរនោះទេគ្រាន់តែគាត់អត់បានសម្រាន្ត និងគាត់គិតបារម្ភច្រើន ហើយពូលាភបានប្រាប់អោយពន្លឺសាកទៅវិទ្យាល័យទៅក្រែងពន្លកនៅសាលា។

... មកដល់វិទ្យាល័យដែលពន្លករៀន ពន្លឺក៏បានសួរពូសន្តិសុខដែលបាននិយាយជាមួយពន្លកកាលពីម្សិលមិញថា ៖

**ពន្លឺ** ៖ សូមអធ្យាស្រ័យពូសន្តិសុខ ពូមានបានប្រទះសិស្សម្នាក់ឈ្មោះ ពន្លក ដែរឬទេ? គាត់ជាប្អូនប្រុសរបស់ខ្ញុំរៀនថ្នាក់ទី ១១។

**ពូសន្តិសុខ** ៖ អូយប្អូន! សិស្សច្រើនសឹងអីពូមិចទៅចាំបានក្មួយមិចម៉ាទៅសួរសិស្សផ្សេងៗដែលប្អូនធ្លាប់ស្គាល់ទៅក្រែងមានតម្រុយ។

**ពន្លឺ** ៖ បាទអរគុណពូ។

ពន្លឺក៏ដើររកពន្លកបន្ត រហូតដល់ពន្លឺបានប្រទះសិស្សមួយក្រុមដែលពូលាភបានសួរនាំកាលពីម្សិលមិញនោះ កំពុងតែរៀនស្វ័យសិក្សាជាក្រុមនៅក្រោមដើមឈើនៅក្នុងវិទ្យាល័យថា ៖

**ពន្លឺ** ៖ ប្អូនៗ ប្អូនៗមានបានប្រទះប្អូនប្រុសរបស់បងឈ្មោះពន្លកដែរឬទេ?

ក្នុងចំណោមសិស្សមួយក្រុមនោះក៏លាន់មាត់ថា ៖

បាត់ពន្លកទៀតហើយ!? បាត់ក៏បាត់ម៉េស ពន្លករាល់ថ្ងៃវាគិតអីទៅ?

**ពន្លឺ** ៖ ប្អូនមានបានប្រទះគាត់ដែរឬទេ?

ក្រុមសិស្សមួយក្រុមនោះឆ្លើយព្រមគ្នាថា ៖

ឃើញច្បាស់ណាស់!!!!

ពន្លឺលឺដូច្នោះក៏មានអារម្មណ៍ថា ៖

**ពន្លឺ** ៖ ចឹងមានន័យថា ...

ក្នុងចំណោមសិស្សមួយក្រុមនោះ មានម្នាក់ប្រាប់ដំណើររឿងថា ៖

បាទបង ! ព្រឹកមិញនេះខ្ញុំបានប្រទះពន្លកមកវិទ្យាល័យទាំងខ្លួនប្រឡាក់សុទ្ធតែដី ខ្ញុំក៏មិនដឹងថាគាត់មកពីណាដែរទេ តែគាត់បានប្រាប់លោកគ្រូជាវិទ្ធថា គាត់បានមានជម្លោះជាមួយលោកពុករបស់គាត់ ហើយបន្ទាប់មកលោកគ្រូជាវិទ្ធបានអោយសម្លៀកបំពាក់គាត់ផ្លាស់ប្តូរដោយឃើញសភាពសម្លៀកបំពាក់របស់ ពន្លកហាក់បីដូចជាកង្វក់។ តែ ...

**ពន្លឺ ៖** តែយ៉ាងម៉េចវិញ?

សិស្សមួយនោះបន្តថា ៖

តែនៅពេលដែលមុនចេញទៅផ្ទះ លឺគាត់បបួលមិត្តរបស់គាត់ថាចេញពីរៀនទៅជុំគ្នានៅហាងកាហ្វេទៀតហើយ។ ខ្ញុំឆ្ងល់ថានៅនោះមានអ្វីពិសេសទៅបែរជានាំគ្នាទៅតែហាងកាហ្វេហ្នឹងចឹង តាមឃើញហាងលក់កាហ្វេ គេលក់តែគ្រឿងកាហ្វេ តែទឹកដោះគោអីហ្នឹង ...

ពេលនោះពន្លឺក៏អរគុណទៅកាន់ក្រុមសិស្សទាំងនោះ ហើយក៏ដើរឆ្ពោះទៅហាងកាហ្វេនោះ។ ពេលទៅដល់ទីកន្លែងលក់កាហ្វេក៏ទិដ្ឋភាពដែលពន្លឺឃើញនោះគឺ ...

ពុទ្ធោពន្លក !!

សម្លេងមួយនេះបានអោយគាត់មានភាពភ្ញាក់ផ្អើលយ៉ាងខ្លាំងនោះគឺ ក្រុមសិស្សដែលជាមិត្តភក្តិរបស់ពន្លកនោះគឺកំពុងតែប្រើប្រាស់គ្រឿងស្រវឹងនិង បារី។ ស្ថានភាពពេលនេះធ្វើឱ្យគាត់ទទួលយកមិនបាននោះទេ។ ពន្លឺពុំជឿសោះថាប្អូនរបស់ខ្លួនហ៊ានប្រព្រឹត្តបែបនេះ។ ពន្លឺក៏ទម្រង់ទៅរកក្រុមមិត្តភក្តិរបស់ពន្លកហើយ ពន្លកងាកក្រោយក៏ឃើញពន្លឺហើយក៏លាន់មាត់ទាំងភាពភ័យខ្លាចថា ៖

បងប្រុស!!!

**ពន្លឺ ៖** មោះទៅផ្ទះ!!!!!

ពន្លឺក៏ចាប់ទាញដៃនាំពន្លកមកផ្ទះ ពេលមកដល់ផ្ទះ ពន្លឺបានណែនាំពន្លកថា ៖

**ពន្លឺ** ៖ មិចបានពន្លកហ៊ានប្រព្រឹត្តរឿងបែប នោះទៅរួច? ហេតុដូចម្ដេចបានទៅជាចឹង? លោកពុកខំចិញ្ចឹមបីបាច់ ឡើងហត់ ដែលមានគិតគូរពីការលះបង់ទឹកចិត្ត កម្លាំង កាយរបស់គាត់អត់? បងមិននឹកស្មានតែពន្លកហ៊ានប្រព្រឹត្ត រឿងបែបនោះសោះ?បងគិតថារកទៅរៀនតនៅភ្នំពេញ រក ការងារនៅភ្នំពេញដើម្បីសម្រួលការងារលោកពុក រកប្រាក់ កម្រៃចិញ្ចឹមលោកពុកនិងពន្លក។ ដល់បងបានឃើញ ទិដ្ឋភាពបែបនោះបងមានអារម្មណ៍ថាខកចិត្ត អស់សង្ឃឹម ចំពោះពន្លកតែម្ដង។ ខ្លួនកំពុងនៅវ័យសិក្សាផង មិចបាន ទៅជាប្រព្រឹត្តរឿងបែបនោះ គ្រឿងស្រវឹងមិនល្អចំពោះ ក្មេងៗដូចជាពួកឯងនោះទេដាច់ខាតតែម្ដងវាជារឿងខុស ច្បាប់ដែលអោយក្មេងប្រព្រឹត្តរឿងអស់ហ្នឹង។

មានដែលនឹកឃើញលោកពុកម្នាក់នោះអត់? គាត់លះបង់អ្វីខ្លះអោយយើងពីរនាក់? គាត់សុខចិត្តប្រកបមុខរបរដែលប្រើប្រាស់កម្លាំងកាយដើម្បីពួកយើងពីរនាក់។ មួយវិញទៀត ពន្លកមានដឹងអត់ថា ការជក់បារីនាំផលប៉ះពាល់អ្វីខ្លះដល់ពន្លក? មុនប្រើប្រាស់វា មានដែលបានគិតគូរពិចារណាអត់? បងពិតជាខ្លោចចិត្តពេលឃើញទិដ្ឋភាពបែបនោះ។ បងពឹងពាក់ពន្លកមិចទៅរួច ប្រសិនបើចេញមកបែបហ្នឹង ។ បងសូមអង្វរណា កុំប្រព្រឹត្តបែបហ្នឹងអីប្រសិនបើស្រលាញ់ខ្លួនឯង លោកពុកនិងបង មនុស្សជុំវិញខ្លួនចូរកុំប្រព្រឹត្តអី។ នៅក្នុងវ័យសិក្សាគិតតែសិក្សាទៅសេពគប់មនុស្សល្អ ខ្លួនកាន់តែធំ ខួរក្បាលកាន់តែអភិវឌ្ឍការគិតកាន់តែស៊ីជម្រៅទៅទៀតចូរពិចារណាអោយបានល្អិតល្អន់ផង។ សំណាងហើយ ដែលពន្លកមិនរៀនប្រព្រឹត្តការឆ្លក់ប្លន់ពីពួកនោះ កុំអីហ្នឹងប្រាកដជាមានរឿងធំជាក់ជាមិនខានប្រសិនបើនៅបន្តនៅជាមួយពួកហ្នឹងទៀត ដឹងតែមានរឿងធំជាក់ជាមិនខាន ពីព្រោះក្រុមមិត្តភក្តិរបស់ពន្លកវាមិនស្រួលទេ។

សំណាងហើយដែលបងបានជួបក្រុមមិត្តភក្តិរួមថ្នាក់របស់ពន្លក កុំអីហ្នឹងមិនដឹងថាពន្លកដល់ណានោះទេ។

ខណៈពេលដែលពន្លឺកំពុងណែនាំពន្លក ស្រាប់តែពូលាភដើរចូលមកបានឃើញកូនពន្លកនៅជាមួយពន្លឺ ពេលនោះហើយដែលសេចក្តីនឹករលឹកចំពោះកូនក៏បង្ហាញក្នុងទិដ្ឋភាពដ៏គួរអោយអាណិត នោះគឺពូលាភបានទៅអោបពន្លកជាមួយនឹងទឹកភ្នែកដែលកំពុងហូរស្រស់ ពូលាភអោបរឹតផងនិយាយទៅកាន់ពន្លកទាំង អារម្មណ៍ក្តុកក្តួលចង់យំនិង ស្ទាបខ្លួនកូនរបស់ខ្លួនថា ៖

**ពូលាភ** ៖ កូនពន្លក ! កូនមានគេវាយដំកូនអត់? កូនបាត់រយៈពេលមួយថ្ងៃនេះកូនទៅទីណា? លោកពុកនឹកកូនណាស់ ទីបំផុតពុកបានជួបកូនហើយ លោកពុកមិនដែលស្អប់ឬទុកកូនមួយណាចោលនោះទេ លោកពុកស្រលាញ់កូនទាំងពីរស្មើៗគ្នា កូនរបស់ពុកមានតែពីរនាក់នេះទេប្រៀបបានដូចជាដុំពេជ្រលោកពុកតែងតែថែទាំថ្នាក់ថ្នមដូចកែវ។

លោកពុកឃើញត្រឡប់មកវិញ លោកពុកធូរក្នុងចិត្តណាស់។ កូនមានដឹងអត់? ពុកគេងមិនលក់មួយយប់ហើយ ដោយសារគិតបារម្ភពីកូនគេបានជួយតាមរកកូនតែមិនឃើញទាល់តែសោះ។ ពេលនេះពុកឃើញកូនមានសុវត្ថិភាព ពុកសប្បាយចិត្តពេកណាស់។ កូនប្រាកដជាឃ្លានហើយ តោះទៅហូបបាយជុំគ្នា។ ពុកតាំងពីព្រឹកមកមិនទាន់ហូបបាយនោះទេពីព្រោះលោកពុកចាំមើលផ្លូវកូនពុកក៏ទើបតែមកពីមន្ទីរពេទ្យដែរ។

លឺពាក្យសម្តីទាំងអស់នេះហើយ ពន្លក និង ពន្លឺក៏ស្រក់ទឹកភ្នែក។ពន្លកក៏លុតជង្គង់បត់ជើងសំពះពូលាភនិយាយទាំងយំថា ៖

**ពន្លក** ៖ លោកពុក អោយកូនសុំទោស កូនមិនគួរណានាំអោយលោកពុកមានរឿងបែបនេះទេ។ សូមលោកពុកអភ័យទោសដល់កូនផង កូននាំអោយលោកពុកពិបាកពេកហើយ។

កូនទទួលស្គាល់ថាកូនបានប្រព្រឹត្តរឿងមិនគប្បី រឿងដែលមិនគួរប្រព្រឹត្ត កូនសន្យាថាកូននឹងខិតខំកែកំហុសដែលកូនបានប្រព្រឹត្តកន្លងមក។ កូននឹងយកគម្រូតាមអ្នកដទៃ និង បងប្រុស។

**ពូលាភ** ៖ ពុកឃើញបែបនេះ លោកពុកមិនដឹងនិយាយអីសមនោះទេមានតែសប្បាយចិត្តពេលកូនដឹងខ្លួនទាន់ពេល និង រៀនកែកំហុសដែលកូនបានប្រព្រឹត្តកន្លងមក មោះកូនទៅងូតទឹកទៅ ប្រញាប់ទៅហូបបាយជុំគ្នាលោកពុកនឹងអោយពន្លឺរៀបចំអោយ ។

នៅក្នុងវ័យសិក្សាគិតតែពីរឿងសិក្សា

ចូរសេពគប់មនុស្សល្អខ្លួនកាន់តែធំ

ខួរក្បាលកាន់តែអភិវឌ្ឍ

ការគិតកាន់តែស៊ីជម្រៅទៅទៀត

ចូរពិចារណាអោយបានល្អិតល្អន់ផង។

- ពន្លឺ

# ការចាកចេញពីផ្ទះ
# របស់ពន្លឺ

ពីរឆ្នាំបានកន្លងផុតទៅ នេះជាការសម្រេចចិត្តយ៉ាងច្បាស់របស់ពន្លឺចំពោះការចាកចេញទៅភ្នំពេញដើម្បីទៅសិក្សានៅសាកលវិទ្យាល័យបន្ត និង រកការងារនៅទីនោះដើម្បីសម្រួលបន្ទុកលោកពុកកុំអោយគាត់លំបាកទ្រាំនឹងការងាររបស់គាត់។ ពន្លកក៏មានការប្រែប្រួលច្រើនផងដែរ ពន្លកចេះមើលថែទាំផ្ទះសម្បែង មើលវាលស្រែគោក្របីស្រែចម្ការ កសិដ្ឋាន មាន់ ទា ជ្រូក ព្រាប រៀបចំទុកដាក់ទ្រព្យសម្បត្តិ មើលខុសត្រូវជុំវិញផ្ទះ ចំអិនម្ហូបអាហារជាដើម។ ពន្លកលែងប្រព្រឹត្តរឿងកាលពីពីរឆ្នាំមុនទៀតហើយ។ នៅយប់មុនពេលដែលពន្លឺចាកចេញពីស្រុកកំណើតទៅភ្នំពេញនោះគាត់បាននាំពូលាភ និង ពន្លកទៅកំសាន្តនៅទីកន្លែងស្អាតៗ សប្បាយជុំគ្នា ជួបជុំនៅអាហារដ្ឋានពីព្រោះគាត់ខានបានហូបអាហារនៅខាងក្រៅយូរហើយ និង អោយជាងថតរូបថតផ្តិតទុកជាអនុស្សាវរីយ៍។ ទិដ្ឋភាពដ៏សប្បាយរីករាយ ស្នាមញញឹមរបស់លោកពុក និង ប្អូនប្រុសបានអោយពន្លឺចងចាំពុំអាចភ្លេចបាននោះទេ។

អារម្មណ៍មួយនៅពេលដែលនរណាម្នាក់បានឃ្លាតចេញពី គ្រួសារ ពីបងប្អូន សាច់ញាតិ ពុកម្តាយ នោះបាននាំអោយ អារម្មណ៍រំជួលស្ទើរតែចង់ហូរទឹកភ្នែក មានអារម្មណ៍ថានឹក ផ្ទះ ស្រុកកំណើតស្រាប់បាត់ទៅហើយ។

ពេលព្រឹកក៏ចូលមកដល់ នេះជាពេលវេលាមួយ ដែលសេចក្តីនឹករលឹកស្រុកកំណើត និង សមាជិកគ្រួសារក៏ កើតមានឡើង។ ពន្លឺក៏បានរៀបចំម្ហូបអាហារដែលខ្លួនបាន ចំអិនជាលើកចុងក្រោយ។

នៅម៉ោង ៩ ព្រឹក ឡានឈ្នួលក៏បានមកដល់មុខផ្ទះ ពូលាភល្មម។ នៅពេលដែលពន្លឺកំពុងដាក់អីវ៉ាន់ចូលទៅ ក្នុងឡានឈ្នួល ពូលាភក៏ចូលមក និយាយទៅកាន់ពន្លឺទាំង ក្តីនឹករលឹកថា ៖

**ពូលាភ ៖** កូនប្រុសសម្លាញ់លោកពុក ចូរកូននឹក ឃើញលោកពុកម្នាក់នេះផង។ ទោះកូនទៅទីណាក៏ដោយ លោកពុកនៅតែនឹកដល់កូនជានិច្ច។ សូមកូនប្រុសសម្លាញ់ របស់ពុកថែរក្សាសុខភាពផងណា ប្រសិនមិនស្រួលអី ឆាប់ មកវិញមកពុកនិងពន្លកនឹងរកចាំមើលផ្លូវ។ សូមអោយ ព្រះជាម្ចាស់តាមថែរក្សាកូនប្រុសរបស់ខ្ញុំអោយមាន សុវត្ថិភាពផងចុះ។

**ពន្លឺ ៖** បាទមិនអីទេលោកពុក លោកពុកក៏ដូចគ្នា ដែលចូរពុកថែរក្សាសុខភាពផង កូនបានសម្រេចចិត្តចេញ ទៅរៀនបន្ត និង រកការងារ រកប្រាក់កម្រៃអោយលោកពុក និង ពន្លកហើយ។ កូនមិនចង់អោយលោកពុកពិបាកទៀត នោះទេ កូនចង់អោយលោកពុកសម្រាកពីការងារម្តង នេះ ជាវេនរបស់កូន កាតព្វកិច្ចរបស់កូនដែលជាបងប្រុសក្នុង គ្រួសារនេះដែលត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងថែទាំ គ្រួសារនេះ។

ពន្លកក៏ដូច្នោះដែរ ប្អូនមានការប្រែប្រួលផងដែរ កុំភ្លេចជួយថែទាំពុកជំនួសបងផង គ្រួសារយើងមានតែបីនាក់នោះទេ។ បងសង្ឃឹមនិងទុកចិត្តលើប្អូនហើយ។

**ពន្លក ៖** បាទបង! ប្អូននឹងថែទាំ មើលខុសត្រូវលោកពុកនិងផ្ទះសម្បែងអោយ។ សូមបងធ្វើដំណើរសុខសប្បាយតាមផ្លូវ ប្អូននឹងប្រឹងអស់ពីសមត្ថភាព និងអរគុណដល់បងប្រុសដែលបានកែតម្រូវប្អូនទាន់ ពុំដូច្នោះទេប្អូនមិនដឹងទៅជាយ៉ាងណានោះទេ។ ប្អូនក៏បានយល់នូវអ្វីដែលគប្បី ឬ មិនគប្បី។ កូនក៏សុំអភ័យទោសដល់លោកពុកដែលមិនបានស្តាប់បង្គាប់ ព្រមទាំងបញ្ចេញនូវអ្វីៗដែលមិនសមរម្យកន្លងមក។ កូនយល់ និងបានក្រែប្រែកំហុសវារួចទៅហើយដូចមានមតិមួយថាមិនខុសមែនគឺ ៖ **« ការស្គាល់កំហុស និង ចេះកែប្រែកំហុសរបស់ខ្លួនធ្វើអោយមនុស្សមានតម្លៃក្នុងសង្គម»**។ ទីបំផុតកូនបានយល់នូវអ្វីដែលខុស និង ត្រូវ។ សូមអរគុណដល់បងពន្លឺម្តងទៀតដែលបានបណ្តុះបណ្តាលប្អូនតាំងពីពេលដែលប្អូនដឹងខ្លួនមក។

មិនអីនោះទេបានបងបណ្តុះបណ្តាល ព្យាយាមពន្យល់បង្រៀនប្អូនកន្លងមកហើយនោះរឿងលោកពុកចាំប្អូនទទួលខុសត្រូវអោយ។

ពេលដែលលឺសម្តីចេញពីមាត់ពន្លកដូច្នោះបានអោយលោកពុក និង ពន្លឺសប្បាយចិត្តក្រៃលែងដែលធ្លាប់គិតថាពន្លកកែមិនកើតក៏ប៉ុន្តែក៏មកពីកត្តាពន្លឺនិង ពូលាភផងដែរ ដែលពួកគាត់ព្យាយាមពន្យល់ណែនាំ តម្រង់ទិសពន្លកអោយប្រព្រឹត្តនូវអ្វីដែលល្អ និងអោយដើរលើវិថីល្អប្រពៃបែបនេះ។

បន្ទាប់ពីបាននិយាយគ្នាចប់រួចរាល់ ពន្លឺក៏អោបលោកពុករបស់ខ្លួន និងប្អូនប្រុសដោយសេចក្តីនឹករលឹកប្រកបដោយភាពកក់ក្តៅ និង សេចក្តីស្រលាញ់ជាពេលចុងក្រោយមុនពេលខ្លួនចេញពីស្រុកកំណើត ដោយមិនដឹងថាពេលណាពន្លឺមកវិញនោះទេពីព្រោះពន្លឺត្រូវប្រកបមុខរបរការងារនៅភ្នំពេញផង រៀននៅសាកលវិទ្យាល័យអោយចប់ចុងចប់ដើមផង។

ពន្លឺក៏បានចាកចេញពីស្រុកកំណើតបាត់ទៅ ...។

*ចប់*

*ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២១*

*ម៉ោង ៣ : ៣៥ នាទីរសៀល*

# តម្លៃអប់រំនៅក្នុងសាច់រឿងទាំងមូល

1. គិតហើយសឹមគូរ កុំគូរហើយបានគិតតាមក្រោយ ព្រោះការធ្វើបែបនេះ នាំឱ្យយើងមានការស្តាយក្រោយ និងមានវិប្បដិសារី។
2. អោយចេះភ្ញាក់រលឹកអ្វីដែលខ្លួនបានប្រព្រឹត្ត។
3. រៀន និង ចេះស្តាប់ដំបូន្មាន ប្រៀនប្រដៅរបស់អ្នកមានគុណ។
4. ទាន់ពួកគាត់នៅមានកម្លាំង មានដង្ហើម ចូរប្រព្រឹត្តតាមអ្វីដែលអ្នកមានគុណប្រាប់ បង្ហាត់បង្រៀន។
5. កុំរឹងរូស និង ប្រើពាក្យសម្តីមិនសមរម្យ។
6. រៀនស្គាល់កំហុស និងចេះកែប្រែកំហុស។
7. ទាន់មានឱកាសចូរកែប្រែទម្លាប់អោយល្អ។
8. រៀនទទួលស្គាល់ ដុសខាត់ខ្លួនឯង។
9. ស្គាល់នូវអ្វីល្អ និង អាក្រក់ គួរឬមិនគួរ។

10. រៀនទទួលនូវមេរៀនជីវិតដែលអ្នកមានគុណបានផ្តល់។

11. រៀនគិតគូរពិចារណា មុនពេលប្រព្រឹត្តអ្វីមួយ។

12. ត្រូវសម្លឹងអោយបានវែងឆ្ងាយមុននឹងប្រព្រឹត្តអ្វីមួយ។

13. យល់ពីទុក្ខលំបាករបស់អ្នកមានគុណ។

14. អ្វីៗដែលពួកគាត់បង្ហាត់បង្រៀន ប្រៀនប្រដៅគឺចង់អោយកូនមានសេចក្តីសុខទៅថ្ងៃមុខ រស់នៅប្រកបដោយសុភមង្គល សុខដុមរមនា។

ក្នុងនាមខ្ញុំបាទជាអ្នកតាក់តែងរឿងខ្នាតខ្លី
មួយនេះក៏សូមអធ្យាស្រ័យក្នុងករណីមានកំហុស
ខុសឆ្គងនៅក្នុងសាច់រឿងខ្នាតខ្លីមួយនេះ
ដោយជាលើកដំបូងក្នុងការតាក់តែងនិងវាយ
សាច់រឿងនេះ។

មានមតិមួយយល់ថា ៖

« ការស្គាល់កំហុស និង ចេះកែប្រែ
កំហុសរបស់ខ្លួនធ្វើអោយមនុស្ស
មានតម្លៃក្នុងសង្គម»។

ប៊ូ វាសនា

(អតីតបេក្ខជនម្ចាស់ជ័យលាភីលេខ ២ ក្នុងការប្រលង
ប្រកួតប្រជែងវណ្ណកម្មកម្រិតយុវជនឆ្នាំ ២០១៩
និង បច្ចុប្បន្នជានិស្សិតឆ្នាំទី១ ផ្នែក អក្សរសាស្ត្រខ្មែរ
នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ)